ក

មាតិកា

I_ខុទ្ទកាល័យព្រះមហាក្សត្រ

១_ព្រះរាជក្រម

០១-៦-២០០៥ -ព្រះរាជក្រម នស/រកម/០៦០៥/០១៦ ច្បាប់ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ ៣៦៥២

២_ព្រះរាជក្រឹត្យ

២១-៥-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៥០៥/២២៧ ស្តីពីការតែងតាំងលោក **គុយ រិន** ជាឧបការី សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា នីតិកាលទី ៣ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ៣៦៦២

២១-៥-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៥០៥/២២៩ ស្តីពីការតែងតាំងលោក **សេខ ឃាក់ស៊្រុន** ជាទីប្រឹក្សាផ្ទាល់ សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា នីតិកាលទី ៣ មានឋានៈស្មើ **រដ្ឋលេខាធិការ** ទទួលបន្ទុកផ្នែកសុខាភិបាល ៣៦៦៣

០១-៦-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៦០៥/២៤៤ ស្តីពីការតែងតាំង ឯកឧត្តម **ញឹក ទីវ៉ាត់** និង ឯកឧត្តម **តាំង សេខហៀង** ជាទីប្រឹក្សារបស់សម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ដោយពុំទទួលប្រាក់បៀវត្ស ៣៦៦៤

០១-៦-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៦០៥/២៤៥ ស្តីពីត្រូវបានបញ្ចប់មុខងារឯកឧត្តម **ជា សុន** ពីទីប្រឹក្សាផ្ទាល់សម្តេច **ជា ស៊ីម** ប្រធានព្រឹទ្ធសភា ដែលត្រូវបានទៅបំពេញភារកិច្ចថ្មី ជាសមាជិកព្រឹទ្ធសភាសំរាប់នីតិកាលទី ១ ៣៦៦៥

០១-៦-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៦០៥/២៤៦ ស្តីពីការតែងតាំង ឯកឧត្តម **យ៉ា គីមហួន** ជាទីប្រឹក្សារបស់អគ្គលេខាធិការព្រឹទ្ធសភាមានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ដោយពុំទទួលប្រាក់បៀវត្ស ៣៦៦៦

០១-៦-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៦០៥/២៤៧ ស្តីពីការតែងតាំង ឯកឧត្តម **សោម សារី** ជាទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ **រដ្ឋមន្ត្រី** ៣៦៦៧

០៩-៦-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៦០៥/២៥៦ ស្តីពីការតែងតាំង :

១- ឯកឧត្តម **គាត ឈន់** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាតំណាងពេញសិទ្ធិប្រចាំមជ្ឈមណ្ឌលអន្តរជាតិសំរាប់ដោះស្រាយវិវាទវិនិយោគ

២- ឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាតំណាងបំរុងប្រចាំមជ្ឈមណ្ឌលអន្តរជាតិសំរាប់ដោះស្រាយវិវាទវិនិយោគ ៣៦៦៨

០៩-៦-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៦០៥/២៥៧ ស្តីពីការតែងតាំង ឯកឧត្តម ចំនួន ០៣ រូប ជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ៣៦៦៩

០៩-៦-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៦០៥/២៥៨ ស្តីពីការផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់អ្នកស្រី **អាលីស គំប៉ាំង** (Alice COMPAIN) សញ្ជាតិដើមអង់គ្លេស កើតនៅក្រុងឡុង ប្រទេសអង់គ្លេស ៣៦៧០

០៩-៦-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៦០៥/២៥៩ ស្តីពីការតែងតាំងលោកស្រី **ស៊ុយ សុផាន** ជា **ឧកញ៉ា** ៣៦៧១

០៩-៦-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៦០៥/២៦០ ស្តីពីការតែងតាំងសមាសភាពថ្នាក់ដឹកនាំរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ចំនួន ០២ រូប ៣៦៧៣

០៩-៦-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៦០៥/២៦១ ស្តីពីការប្រោសព្រះរាជទាននូវ **គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា** តាមលំដាប់ថ្នាក់ ជូន ឯកឧត្តម និងលោកជំទាវ ចំនួន ០៥ រូប ៣៦៧៤

០៩-៦-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៦០៥/២៦២ ស្តីពីការតែងតាំងឯកឧត្តម **ខាច់ យន** ជា អនុប្រធាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានឋានៈស្មើ **រដ្ឋមន្ត្រី** ៣៦៧៥

០៩-៦-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៦០៥/២៦៣ ស្តីពីការតែងតាំងឯកឧត្តម **រ័ត្ន សុវណ្ណារ៉ាប់** ជា អនុប្រធាននៃអាជ្ញាធរជាតិទេសចរណ៍កម្ពុជា មានឋានៈស្មើ **រដ្ឋលេខាធិការ** ៣៦៧៦

០៩-៦-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៦០៥/២៦៤ ស្តីពីការបន្ថយរយៈពេលទទួលរងទោសឱ្យទណ្ឌិត ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមក ៣៦៧៧

១៣-៦-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៦០៥/២៦៩ ស្តីពីការតែងតាំង ឯកឧត្តម **ម៉ម ប៊ុននាង** ជាទីប្រឹក្សាផ្ទាល់ សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា នីតិកាលទី ៣ មានឋានៈស្មើ **រដ្ឋមន្ត្រី** ដោយ ពុំទទួលប្រាក់បៀវត្ស ៣៦៨៣

១៣-៦-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៦០៥/២៧០ ស្តីពីការតែងតាំង ឯកឧត្តម ឧត្តមសេនីយ៍ត្រី **គង់ ចន្ថី** ជាទីប្រឹក្សាផ្ទាល់ សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា នីតិកាល ទី ៣ មានឋានៈស្មើ **រដ្ឋលេខាធិការ** ដោយ ពុំទទួលប្រាក់បៀវត្ស ៣៦៨៤

១៣-៦-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៦០៥/២៧១ ស្តីពីការតែងតាំង ឯកឧត្តម **ខឹន នាង** ជាទីប្រឹក្សាផ្ទាល់ សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធាន រដ្ឋសភា នីតិកាល ទី ៣ មានឋានៈស្មើ **រដ្ឋលេខាធិការ** ដោយ ពុំទទួលប្រាក់បៀវត្ស ៣៦៨៥

១៣-៦-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៦០៥/២៧២ ស្តីពីការតែងតាំង ឯកឧត្តម **ឃ្លាំង ហួត** ជាទីប្រឹក្សាផ្ទាល់ សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធាន រដ្ឋសភា នីតិកាល ទី ៣ មានឋានៈស្មើ **រដ្ឋលេខាធិការ** ដោយ ពុំទទួលប្រាក់បៀវត្ស ៣៦៨៦

១៤-៦-២០០៥ -ព្រះរាជក្រឹត្យ នស/រកត/០៦០៥/២៧៥ ស្តីពីការកែសម្រួលមាត្រា ១ មាត្រា ២ មាត្រា៣ មាត្រា៤ មាត្រា៥ មាត្រា៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៦/២៥ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៦ ៣៦៨៦

II. រាជរដ្ឋាភិបាល

១. អនុក្រឹត្យ

១០-៦-២០០៥ -អនុក្រឹត្យលេខ ៨០ អនក្រ.បក ស្តីពីការគ្រប់គ្រងសបាតមន៍នេសាទ ៣៦៩២

១០-៦-២០០៥ -អនុក្រឹត្យលេខ ៨១ អនក្រ.បក ស្តីពីការប្រើប្រាស់គណនីឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ ៣៦៩២

១៤-៦-២០០៥ -អនុក្រឹត្យលេខ ៨២ អនក្រ.បក ស្តីពីការតំឡើងការិយាល័យអាស៊ាននិងអង្គការពាណិជកម្មពិភពលោក (WTO) ទៅជានាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិនៃក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ៣៧០៩

០៩-៦-២០០៥ -អនុក្រឹត្យលេខ ៩០០ អនក្រ.គត ស្តីពីការជូនមេដាយសបាមេត្រី ៣៧១២

០៩-៦-២០០៥ -អនុក្រឹត្យលេខ ៥០១ អនក្រ.តត ស្ដីពីការជូនមេដាយការងារ ៣៧១៤
០៩-៦-២០០៥ -អនុក្រឹត្យលេខ ៥០២ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៣៧១៦
១០-៦-២០០៥ -អនុក្រឹត្យលេខ ៥០៣ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៣៧១៨
១០-៦-២០០៥ -អនុក្រឹត្យលេខ ៥០៤ អនក្រ.តត ស្ដីពីការជូនមេដាយសហមេត្រី ៣៧១៩
១០-៦-២០០៥ -អនុក្រឹត្យលេខ ៥០៥ អនក្រ.តត ស្ដីពីការជូនមេដាយសហមេត្រី ៣៧២០
១៣-៦-២០០៥ -អនុក្រឹត្យលេខ ៥០៦ អនក្រ.តត ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៣៧២២
១៤-៦-២០០៥ -អនុក្រឹត្យលេខ ៥០៧ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ៣៧២៤
១៤-៦-២០០៥ -អនុក្រឹត្យលេខ ៥០៨ អនក្រ.តត ស្ដីពីការតែងតាំងមន្ត្រីរាជការ ៣៧២៥
១៤-៦-២០០៥ -អនុក្រឹត្យលេខ ៥០៩ អនក្រ.តត ស្ដីពីការជូនមេដាយសហមេត្រី ៣៧២៧
១៤-៦-២០០៥ -អនុក្រឹត្យលេខ ៥១០ អនក្រ.តត ស្ដីពីការលុបឈ្មោះ និងប្រគល់ភារកិច្ចជូនមន្ត្រីរាជការ ៣៧២៨

២. សេចក្ដីសំរេច

១៥-៦-២០០៥ -សេចក្ដីសំរេចលេខ ១៥ សសរ ស្ដីពីការរៀបចំការចងសម្ព័ន្ធមេត្រីភាពរវាងអង្គភាពកង
ទ័ព ជាមួយស្ថាប័ន អង្គភាពស៊ីវិល ៣៧៣០

III. ការងារបណ្ដាក្រសួង

ទីស្ដីការរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

៣១-៥-២០០៥ -លិខិតលេខ ១២៣៤ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
យូនីក ឡូជីស្ទីក អ៊ិនធើណេសិនណល (ខេមបូឌា) ៣៧៣៣
៣១-៥-២០០៥ -លិខិតលេខ ១២៣៦ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ខ្មែរ ហ្វូន ស៊ីលូសិន លីមីធីត ៣៧៣៥
៣១-៥-២០០៥ -លិខិតលេខ ១២៣៧ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ហ្វា ស៊ុី ហ្គាមេន ៣៧៣៧
៣១-៥-២០០៥ -លិខិតលេខ ១២៣៨ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ក្វាតា យូមេន វីសស៍ លីមីធីត ៣៧៣៨
៣១-៥-២០០៥ -លិខិតលេខ ១២៤១ ពណ.នតក ស្ដីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ម៉ៅ នី ៣៧៤០

៣១-៥-២០០៥ -លិខិតលេខ ១២៤២ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ហូណូលូលូ ខេហ្វេ លីមីធីត ៣៧៤២

៣១-៥-២០០៥ -លិខិតលេខ ១២៤៣ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
អូអាស៊ីស ខូ អិលធីឌី ៣៧៤៤

៣១-៥-២០០៥ -លិខិតលេខ ១២៥២ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ឌុង ហ្វ៊ីត អ៊ិនវេសមេន គ្រុប ៣៧៤៦

០១-៦-២០០៥ -លិខិតលេខ ១២៥៤ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ទ័នឌើរ ទើ ត្រេឌីង ៣៧៤៨

០១-៦-២០០៥ -លិខិតលេខ ១២៥៦ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
អេមឌីរើរ កាហ្វេ លីមីធីត ៣៧៥០

០១-៦-២០០៥ -លិខិតលេខ ១២៥៩ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ម៉ូណាកូ ខបភើរេសិន ៣៧៥២

០២-៦-២០០៥ -លិខិតលេខ ១២៧០ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ភ្នំពេញ ផាប់ប្លីក អ៊ិនធើប្រាយ ៣៧៥៤

០២-៦-២០០៥ -លិខិតលេខ ១២៧៤ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
តាំង សៀមហួន អ៊ីមផត អិចផត ៣៧៥៦

០៦-៦-២០០៥ -លិខិតលេខ ១២៩៤ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
អានណា ហូលឌីង (ខេមបូឌា) ៣៧៥៨

០៦-៦-២០០៥ -លិខិតលេខ ១២៩៥ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ទូហ្គោ ៣៧៦០

០៦-៦-២០០៥ -លិខិតលេខ ១២៩៦ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ខេ.ខេ.ភី. គ្រុប អិលធីឌី ៣៧៦២

០៦-៦-២០០៥ -លិខិតលេខ ១២៩៧ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ធនាគារឯកទេសវិនិយោគទីមួយ ៣៧៦៤

០៦-៦-២០០៥ -លិខិតលេខ ១២៩៨ ពណ.នតក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
អិម ធី ស៊ី អ៊ីមផត អិចផត ៣៧៦៦

០៦-៦-២០០៥ -លិខិតលេខ ១២៤២ ពណ.នគក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ទូរី ខបតើរេសិន ៣៧៦៨

០៦-៦-២០០៥ -លិខិតលេខ ១៣០២ ពណ.នគក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
មករា ភ្នំមាស (ខេមបូឌា) ៣៧៧០

០៦-៦-២០០៥ -លិខិតលេខ ១៣០៣ ពណ.នគក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
អង្គរ វើលដ៍ ត្រាវែល & ធួរ ៣៧៧១

០៨-៦-២០០៥ -លិខិតលេខ ១៣២២ ពណ.នគក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
វ៉ាយខេម ខបតើរេសិន ៣៧៧៣

០៨-៦-២០០៥ -លិខិតលេខ ១៣២៤ ពណ.នគក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ខេ ២ ផៅវ័រ អេនើជី (ខេមបូឌា) ៣៧៧៥

០៨-៦-២០០៥ -លិខិតលេខ ១៣២៥ ពណ.នគក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
លាង ណាត អេខ ៣៧៧៧

០៩-៦-២០០៥ -លិខិតលេខ ១៣២៦ ពណ.នគក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ហ្គ្រីន អេទី (ខេមបូឌា) ៣៧៧៩

០៩-៦-២០០៥ -លិខិតលេខ ១៣២៧ ពណ.នគក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ហ្គោលដេន រតនា ៣៧៨១

០៩-៦-២០០៥ -លិខិតលេខ ១៣២៨ ពណ.នគក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
សុវណ្ណ រាជសីហ៍ ៣៧៨៣

០៩-៦-២០០៥ -លិខិតលេខ ១៣២៩ ពណ.នគក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
សុវណ្ណ គីរី ៣៧៨៥

០៩-៦-២០០៥ -លិខិតលេខ ១៣៣០ ពណ.នគក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
សុវណ្ណ សាគរ ៣៧៨៧

០៩-៦-២០០៥ -លិខិតលេខ ១៣៣១ ពណ.នគក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ជេ អាយ ធី អ៊ិនជីនារីង ៣៧៨៩

០៩-៦-២០០៥ -លិខិតលេខ ១៣៣៨ ពណ.នគក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន
ដា ចំណាន ឡាបូរ៉ាន់រ ៣៧៩១

០៩-៦-២០០៥	-លិខិតលេខ ១៣៣៩ ពណ.នគក ស្តីពី ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មរបស់ក្រុមហ៊ុន **ឡាយហ្វ៊ូ ជីន ខូ អិលធីឌី**	៣៧៩២
១៥-៦-២០០៥	-ប្រកាសលេខ ១៨៥ MOC/SM 2005 ស្តីពី ស្ថានភាពរោងចក្រកាត់ដេរមួយចំនួន នៅកម្ពុជា	៣៧៩៤
15-6-2005	-PRAKAS N° 185 MOC/SM 2005 On The Status of Some Garment Factories in Cambodia	៣៧៩៦
១៥-៦-២០០៥	-ប្រកាសលេខ ១៨៦ MOC/SM 2005 ស្តីពី ស្ថានភាពរោងចក្រកាត់ដេរ MIGHTI-SPECTRA KNITTING FACTORY LTD.	៣៧៩៧
15-6-2005	-PRAKAS N° 186 MOC/SM 2005 On The Status of MIGHTI-SPECTRA KNITTING FACTORY LTD. InCambodia	៣៧៩៩

ព្រះរាជក្រម

នស/រកម/០៦០៥/០១៦

យើង

ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់ យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋា-ភិបាលកម្ពុជា និងរបស់ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ ដែលរដ្ឋសភាបាន អនុម័តកាលពីថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គរបស់ រដ្ឋសភាលើកទី ២ នីតិកាលទី ៣ ហើយដែលព្រឹទ្ធសភា បានអនុម័តយល់ស្រប លើទម្រង់និងគតិនៃច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០០៥ នាសម័យប្រជុំពេញអង្គលើកទី ៩ នីតិកាលទី ១ ហើយដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

ច្បាប់

ស្តីពី

ការគ្រប់គ្រងអាវុធ

គ្រឿងផ្ទុះ និងគ្រាប់រំសេវ

3/11

ជំពូកទី ១

បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

ច្បាប់នេះមានគោលដៅកំណត់ការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ២.-

វិសាលភាពនៃច្បាប់នេះគ្របដណ្តប់លើការបំពាក់ ការកាន់កាប់ ការយកតាមខ្លួន ការប្រើប្រាស់ ការទិញ ការលក់ ការធ្វើពាណិជ្ជកម្ម ការឱ្យខ្ចី ការផ្ទេរ ការចែកចាយ ការជួល ការផលិត ការកែច្នៃតម្លើង ការផ្គុំសផុល ការដឹកជញ្ជូន ការនាំឆ្លងកាត់ ការនាំចូល ការនាំចេញ ការស្តុកអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ។

មាត្រា ៣.-

វាក្យសព្ទ ដូចចែងក្នុងច្បាប់នេះ មាននិយមន័យដូចខាងក្រោម :

ក-អាវុធសំដៅដល់កាំភ្លើងគ្រប់ប្រភេទ ដែលផលិត ឬ កែច្នៃតម្លើង ដែលអាចប្រើប្រាស់សម្លាប់ ឬ ធ្វើឱ្យរបួស ឬ ធ្វើឱ្យប៉ះពាល់ខូចខាតដល់ទ្រព្យសម្បត្តិ ។

ខ-គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ សំដៅដល់ឧបករណ៍ សម្ភារៈ ដែលគេផលិត ឬ កែច្នៃ តម្លើង ដែលអាចប្រើប្រាស់សម្លាប់ ឬ ធ្វើឱ្យរបួស ឬ ធ្វើឱ្យប៉ះពាល់ដល់ទ្រព្យសម្បត្តិ ។

គ-អាវុធគីមី អាវុធជីវសាស្ត្រគ្រប់ប្រភេទ ឬ គ្រាប់ដទៃទៀត ដែលផ្ទុកជាតិគីមី ផ្ទុកជីវសាស្ត្រ សំដៅដល់សារធាតុដែលគេផលិត ឬ កែច្នៃតម្លើងអាចបង្កគ្រោះថ្នាក់ដល់សុខភាព អាយុជីវិត ឬ ទ្រព្យសម្បត្តិ និង បរិស្ថាន ។

ឃ-កងកម្លាំងឯកសណ្ឋាន សំដៅដល់កងកម្លាំងនគរបាលជាតិ និងកងយោធពលខេមរភូមិន្ទ ។

ង-មន្ត្រី សំដៅដល់អ្នករាជការក្នុងក្របខ័ណ្ឌមុខងារសាធារណៈទាំងឡាយនិងមន្ត្រីតុលាការ មន្ត្រីនៃស្ថាប័នកំពូលរបស់ជាតិ ។

ច-ជនស៊ីវិលសំដៅដល់ជនទាំងឡាយ ដែលមិនស្ថិតនៅក្នុងកថាខណ្ឌ ឃ និង ង ។

ជំពូកទី ២
ការគ្រប់គ្រង ការផ្គត់ផ្គង់
ការដឹកជញ្ជូន អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ

មាត្រា ៤.-

ត្រូវហាមឃាត់ ការបំពាក់ ការកាន់កាប់ ការយកតាមខ្លួន ការប្រើប្រាស់ ការទិញ ការលក់ ការធ្វើពាណិជ្ជកម្ម ការឱ្យខ្ចី ការផ្ទេរ ការចែកចាយ ការជួល ការផលិត ការកែច្នៃតម្លើង ការជួសជុល ការដឹកជញ្ជូន ការនាំឆ្លងកាត់ ការនាំចូល ការនាំចេញ ការស្តុកអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ គ្រប់ប្រភេទ ចំពោះជនស៊ីវិលក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៥.-

ត្រូវបានអនុញ្ញាតអោយជនស៊ីវិលប្រើប្រាស់កាំភ្លើង គ្រាប់បាញ់ និងគ្រឿងផ្ទុះ ដែលមិនស្ថិតនៅក្នុងកថាខណ្ឌ ក , ខ, គ នៃមាត្រា ៣ ក្នុងច្បាប់នេះ :

- កាំភ្លើង និង គ្រាប់បាញ់កំណត់សញ្ញា
- កាំភ្លើង និង គ្រាប់បាញ់សម្រាប់សកម្មភាពកីឡា
- កាំភ្លើងដែលបាញ់ មិនមានបញ្ចូនក្បាលគ្រាប់ ឬ គ្រាប់ប្រាយ ។ កាំភ្លើងបាញ់បញ្ចូនកាំជ្រួចលំអ ឬ កាំភ្លើងផ្ទុះសូរគ្មានក្បាលគ្រាប់សំរាប់សំដែងសិល្បៈ ។
- គ្រឿងផ្ទុះសម្រាប់បម្រើសេវាកម្មសាធារណៈ និង វិស្វកម្មស៊ីវិល ឬ សម្រាប់ផ្ទុះលំអ ។

ល័ក្ខខ័ណ្ឌ និង នីតិវិធី សម្រាប់អនុវត្តមាត្រានេះ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ក្រសួងមហាផ្ទៃ ។

មាត្រា ៦.-

ត្រូវបានអនុញ្ញាតឱ្យតែក្រសួងមហាផ្ទៃ និង ក្រសួងការពារជាតិមានក្លឹប និង ទីលានសម្រាប់ហាត់បាញ់ដើម្បីហ្វឹកហ្វឺន ។

មាត្រា ៧.-

ការបំពាក់ ការកាន់កាប់ ការយកតាមខ្លួន ការប្រើប្រាស់ ការទិញ ការលក់ ការធ្វើពាណិជ្ជកម្ម ការឱ្យខ្ចី ការផ្ទេរ ការចែកចាយ ការជួល ការផលិត ការកែច្នៃតម្លើង ការជួស

5/11

ជុល ការដឹកជញ្ជូន ការនាំឆ្លងកាត់ ការនាំចូល ការនាំចេញ ការស្តុកអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដល់កងកម្លាំងឯកសណ្ឋាន និង មន្ត្រី ត្រូវស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់នេះ ។

មាត្រា ៨.-

ជនបរទេស មិនត្រូវបានអនុញ្ញាតឱ្យកាន់កាប់ ឬ ប្រើប្រាស់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

តាមសំណើសុំជាផ្លូវការ រាជរដ្ឋាភិបាលអាចផ្តល់ការលើកលែងចំពោះអង្គរក្សបរទេសមាន : អង្គរក្សរបស់ព្រះមហាក្សត្រ ឬ ព្រះមហាក្សត្រីយានី ប្រធានាធិបតី ប្រមុខរដ្ឋ នាយករដ្ឋមន្ត្រី ឥស្សរជនជាន់ខ្ពស់ ដែលយាង ឬ អញ្ជើញមកធ្វើទស្សនកិច្ច នៅព្រះរាជាណាចក្រកម្ពុជា ។

មាត្រា ៩.-

ការចុះបញ្ជីគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាសមត្ថកិច្ចរបស់ក្រសួងការពារជាតិ និង ក្រសួងមហាផ្ទៃ ។

មាត្រា ១០.-

ក្រសួងការពារជាតិ ទទួលខុសត្រូវលើការផ្គត់ផ្គង់ ការត្រួតពិនិត្យ ការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទរបស់កងយោធពលខេមរភូមិន្ទ ។

ក្រសួងមហាផ្ទៃ ទទួលខុសត្រូវលើការផ្គត់ផ្គង់ ការត្រួតពិនិត្យ ការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទរបស់កងកម្លាំងនគរបាលជាតិ ស្ថាប័នសាធារណៈ មន្ត្រី និង ជនស៊ីវិល ។

មាត្រា ១១.-

ក្រសួងការពារជាតិ មានសមត្ថកិច្ចចេញប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដល់កងយោធពលខេមរភូមិន្ទ ។

ក្រសួងមហាផ្ទៃ មានសមត្ថកិច្ចចេញប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដល់កងកម្លាំងនគរបាលជាតិ ស្ថាប័នសាធារណៈ មន្ត្រី និង ជនស៊ីវិល ។

ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ ត្រូវមានបញ្ជាក់អំពីប្រភេទអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ និងល័ក្ខខ័ណ្ឌដែលត្រូវគោរព ។

ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវរបស់អង្គភាព ត្រូវបានបញ្ជាក់បន្ថែមអំពីកាតព្វកិច្ចតម្រូវឱ្យយកអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវមករក្សាទុកក្នុងឃ្លាំងវិញ ។

នីតិវិធី និង ល័ក្ខខ័ណ្ឌ ស្តីពីការសុំប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ១២.-

ក្រសួងការពារជាតិ ទទួលខុសត្រូវលើសុវត្ថិភាព និង សន្តិសុខស្តុកទុកអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទរបស់កងយោធពលខេមរភូមិន្ទ ។

ក្រសួងមហាផ្ទៃ ទទួលខុសត្រូវលើសុវត្ថិភាព និង សន្តិសុខស្តុកទុកអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទរបស់កងកម្លាំងនគរបាលជាតិ ស្ថាប័នសាធារណៈ មន្ត្រីនិងជនស៊ីវិល ។

អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវទាំងអស់ត្រូវចុះក្នុងបញ្ជី ហើយអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទត្រូវតែស្តុកទុក និងបញ្ចូលក្នុងឃ្លាំងដែលមានសុវត្ថិភាព ។

មាត្រា ១៣.-

ដើម្បីធានាសុវត្ថិភាពសាធារណៈ និង ដើម្បីបង្ការទប់ស្កាត់គ្រោះមហន្តរាយដល់អាយុជីវិត ឬ ទ្រព្យសម្បត្តិ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬ រដ្ឋមន្ត្រីក្រសួងការពារជាតិ អាចបញ្ជាឱ្យជន្លៀសសាធារណជន ចេញជាបណ្តោះអាសន្នពីលំនៅដ្ឋាន ឬ តំបន់ ក្នុងករណីដឹងថាមានគ្រោះថ្នាក់កើតឡើង ។

បែបបទនៃការអនុវត្តមាត្រានេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

មាត្រា ១៤.-

ការដឹកជញ្ជូនអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទក្នុងប្រទេសត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងការពារជាតិ បើក្នុងគោលដៅការពារជាតិ ឬ របស់ក្រសួងមហាផ្ទៃ បើក្នុងគោលដៅការពារសន្តិសុខផ្ទៃក្នុងប្រទេស ។

ការដឹកជញ្ជូនអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទឆ្លងកាត់ព្រះរាជាណាចក្រកម្ពុជា មកពីក្រៅប្រទេសអាចធ្វើទៅបាន លុះត្រាតែបានការយល់ព្រមពីរាជរដ្ឋាភិបាលតាមសំណើរបស់ក្រសួងការពារជាតិ និង ក្រសួងមហាផ្ទៃ ។

មាត្រា ១៥.-

ករណីបាត់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ដែលបាននិងកំពុងកាន់កាប់ប្រើប្រាស់ ហើយការបាត់នោះកើតឡើងនៅក្រៅអង្គភាព ត្រូវរាយការណ៍មិនលើសពី ២៤ (ម្ភៃបួន)ម៉ោង ក្រោយពេលដឹងថាបាត់ ដល់ប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ-សង្កាត់ ឬ ប៉ុស្តិ៍ កងរាជអាវុធហត្ថ នៅទីកន្លែងដែលបាត់ ហើយត្រូវមានសាក្សីដឹងឮម្នាក់ ឬ ពីរនាក់ទៅជាមួយផងនៅពេលរាយការណ៍ ។ ក្នុងករណីគ្មានសាក្សី សមត្ថកិច្ចនៅកន្លែងកើតហេតុ ត្រូវចុះត្រួតពិនិត្យ និងធ្វើកំណត់ហេតុដល់ទីកន្លែងដែលបាត់ ។

ករណីបាត់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ដែលស្តុកទុកក្នុងឃ្លាំង ឬ ក្នុងអង្គភាព នាយឆ្មាំ ឬ អ្នកទទួលខុសត្រូវថែរក្សា ត្រូវរាយការណ៍ដល់មេបញ្ជាការ ឬ ប្រធានអង្គភាព មិនលើសពី ២៤ (ម្ភៃបួន)ម៉ោង ក្រោយដឹងថាបាត់ ។ មេបញ្ជាការ ឬ ប្រធានអង្គភាព ត្រូវចាត់វិធានការត្រួតពិនិត្យស្រាវជ្រាវជាបន្ទាន់ ។

របាយការណ៍ស្តីពីការបាត់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទខាងលើនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរដោយបញ្ជាក់លំអិតទាក់ទងនឹងប្រភេទអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ លេខចុះបញ្ជី ព្រមទាំងមូលហេតុ និង កាលៈទេសៈនៃការបាត់ ។

មាត្រា ១៦.-

ការបំផ្លាញអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ឬ ការលុបចេញពីបញ្ជី ត្រូវមានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បើអាវុធ គ្រឿងផ្ទុះនិងគ្រាប់រំសេវគ្រប់ប្រភេទនោះ ស្ថិតក្នុងសមត្ថកិច្ចរបស់ក្រសួងមហាផ្ទៃ ឬ មានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងការពារជាតិ បើអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទនោះ ស្ថិតក្នុងសមត្ថកិច្ចរបស់ក្រសួងការពារជាតិ ។

មាត្រា ១៧.-

ក្នុងករណីចាំបាច់រាជរដ្ឋាភិបាលអាចបង្កើតគណៈកម្មការជាតិ ដើម្បីត្រួតពិនិត្យដឹកនាំ ឬ កែទម្រង់ការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

ជំពូកទី ៣
ការនាំចូល ការនាំចេញ ការជួសជុល ការផលិតអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ

មាត្រា ១៨.-

ការនាំចូល ការនាំចេញ ការជួសជុល ការផលិតអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទជាសមត្ថកិច្ចរបស់រាជរដ្ឋាភិបាល ។

ក្រសួងការពារជាតិនិងក្រសួងមហាផ្ទៃ ត្រូវបានអនុញ្ញាតឱ្យមានរោងជាងជួសជុល និងទីតាំងសម្រាប់ធ្វើការសាកល្បងគុណភាពអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ។

ការនាំចូល ការនាំចេញ ការផលិតអាវុធ គ្រឿងផ្ទុះ គ្រាប់រំសេវគ្រប់ប្រភេទ ត្រូវស្របតាមគោលការណ៍ និងវិធានទាំងឡាយរបស់អន្តរជាតិដែលពាក់ព័ន្ធ ។

ជំពូកទី ៤
ទោសប្បញ្ញត្តិ

មាត្រា ១៩.-

ជនណាដែលប្រព្រឹត្តផ្ទុយនឹងមាត្រា ១៥ និងមាត្រា ១៦ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៣(បី)ខែ ដល់១ (មួយ)ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ២០០.០០០ (ម្ភៃម៉ឺន)រៀល ដល់១.០០០.០០០(មួយលាន)រៀល ដោយពុំទាន់គិតពីបទល្មើសព្រហ្មទណ្ឌផ្សេងទៀត ។

មាត្រា ២០.-

ជនណាដែលបំពាក់ដាក់តាមខ្លួន កាន់កាប់ ប្រើប្រាស់ លក់ ទិញ ឱ្យខ្ចី ផ្ទេរ ចែកចាយ ជួល កែច្នៃតម្លើង ជួសជុល នូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ)ខែ ដល់២ (ពីរ) ឆ្នាំ និងត្រូវផ្តន្ទា-

ទោសពិន័យជាប្រាក់ពី ៥០០.០០០ (ហាសិបម៉ឺន)រៀល ដល់ ២.០០០.០០០ (ពីរលាន)រៀល ដោយពុំទាន់គិតពីបទល្មើសព្រហ្មទណ្ឌផ្សេងទៀត ។

មាត្រា ២១.-

ជនណាដែលឆ្វេសប្រហែសឱ្យជនដទៃយកអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ដែលខ្លួនកាន់កាប់ទៅប្រើប្រាស់ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ឆ្នាំ ដល់ ២ (ពីរ) ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៧០០.០០០ (ចិតសិបម៉ឺន)រៀលដល់ ២.០០០.០០០ (ពីរលាន) រៀល ។

មាត្រា ២២.-

មន្ត្រីដែលក្រសួងមានសមត្ថកិច្ច ប្រគល់ឱ្យចេញប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធ គ្រឿងផ្ទុះ និង គ្រាប់រំសេវគ្រប់ប្រភេទ តែការផ្តល់ប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់នោះពុំបានត្រឹមត្រូវខុសសមត្ថកិច្ចរបស់ខ្លួន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ)ឆ្នាំ ដល់ ៥ (ប្រាំ) ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៣.០០០.០០០ (បីលាន)រៀល ដល់ ៦.០០០.០០០ (ប្រាំមួយលាន)រៀល ។

ជនណាដែលពុំមែនជាសមត្ថកិច្ច ហើយបានចេញប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធ គ្រឿងផ្ទុះ និង គ្រាប់រំសេវគ្រប់ប្រភេទក្រោមរូបភាពណាមួយ ឬ ដោយមូលហេតុណាក៏ដោយ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ)ឆ្នាំ ដល់ ៨ (ប្រាំបី)ឆ្នាំ និងត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ៤.០០០.០០០ (បួនលាន)រៀល ដល់ ១០.០០០.០០០ (ដប់លាន)រៀល ។

ជនណាដែលធ្វើប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយក្លែងបន្លំ ឬ បានប្រើប័ណ្ណសម្គាល់សិទ្ធិប្រើប្រាស់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយដឹងថាក្លែងបន្លំ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ដល់ ១០ (ដប់) ឆ្នាំ ។

មាត្រា ២៣.-

ជនណាដែលផលិត ធ្វើពាណិជ្ជកម្ម នាំឆ្លងកាត់ នាំចេញ នាំចូល ឬ ស្តុកទុកអាវុធគ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទដោយគ្មានការអនុញ្ញាត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំ ដល់ ១០ (ដប់)ឆ្នាំ ។

មាត្រា ២៤.–

ជនណាដែលបានប្រព្រឹត្តផ្ទុយនឹងមាត្រា ៨ និងមាត្រា ១៤ នៃច្បាប់នេះ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ)ឆ្នាំ ដល់ ១០ (ដប់) ឆ្នាំ ដោយពុំទាន់គិតពីបទល្មើសព្រហ្មទណ្ឌផ្សេងទៀត ។

ជំពូកទី ៥
អន្តរប្បញ្ញត្តិ

មាត្រា ២៥.–

ក្នុងរយៈពេល ៣ (បី)ខែ យ៉ាងយូរ បន្ទាប់ពីច្បាប់នេះចូលជាធរមាន ជនណាដែលបានកាន់កាប់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ដោយគ្មានការអនុញ្ញាតត្រូវយកអាវុធ គ្រឿងផ្ទុះ និង គ្រាប់រំសេវគ្រប់ប្រភេទទាំងនោះ មកប្រគល់ឱ្យអាជ្ញាធរមានសមត្ថកិច្ច ។

ជំពូកទី ៦
អវសានប្បញ្ញត្តិ

មាត្រា ២៦.–

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងច្បាប់នេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ២៧.–

ច្បាប់នេះត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០០៥

នស.០៥០៦.២៦៧ **ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
នរោត្តម សីហមុនី

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ
នាយករដ្ឋមន្ត្រី
ហត្ថលេខា
ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
ឧបនាយករដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
ហត្ថលេខា និងព្រះហស្តលេខា
ស ខេង នរោត្តម សិរីវុឌ្ឍ

លេខ ... ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
សាខី តាន់

ព្រះរាជក្រឹត្យ

នស/រកត/០៥០៥/២២៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរះដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោរាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៣ នៃរដ្ឋសភា នាថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ និង ថ្នាក់ដឹកនាំរដ្ឋសភា និង សំដែងការទុកចិត្ត ទៅលើសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចក្រុមព្រះ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងលោក ទួយ រិន ជាឧបការី សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ព្រះប្រធានរដ្ឋសភា នីតិកាលទិ៣ មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ។

មាត្រា ២ : ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ឱ្យបានសម្រេច ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៥០៥.៧៤៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៥

លេខ : ៧៧៦ ច.ល
ចម្លងចេញពីច្បាប់ដើម
រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

សុខ តាន់

ព្រះរាជក្រឹត្យ

នស/រកត/០៥០៥/២២៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៣ នៃរដ្ឋសភា នាថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ និង ថ្នាក់ដឹកនាំរដ្ឋសភា និង សំដែងការទុកចិត្ត ទៅលើសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចក្រុមព្រះ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងលោក សេង ហាក់ស្រ៊ុន ជាទីប្រឹក្សាផ្ទាល់ សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ព្រះប្រធានរដ្ឋសភា នីតិកាលទី៣ មានឋានៈស្មើ រដ្ឋលេខាធិការ ទទួលបន្ទុកផ្នែកសុខាភិបាល ។

មាត្រា ២ : ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ឱ្យបានសំរេច ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

ចារ-០៥០៥.២៤៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ ឧសភា ឆ្នាំ ២០០៥

លេខ : ៥៥៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible] តាន់

ព្រះរាជក្រឹត្យ

នស/រកត/០៦០៥/២៤៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលប្រកាសបង្គាប់ឱ្យប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័ត នៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចប្រធានព្រឹទ្ធសភា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំង :

- ឯកឧត្តម ញឹក ទីវ៉ាត់ ជាទីប្រឹក្សារបស់សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា មានឋានៈស្មើអនុរដ្ឋលេខាធិការ ដោយពុំទទួលប្រាក់បៀវត្ស ។
- ឯកឧត្តម តាន់ សេងហៀង ជាទីប្រឹក្សារបស់សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា មានឋានៈស្មើអនុរដ្ឋលេខាធិការ ដោយពុំទទួលប្រាក់បៀវត្ស ។

មាត្រា ២ : ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧៤.០៥០៦.២៥៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០០៥

លេខ : ៥៨៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ាវី តាន់

ព្រះរាជក្រឹត្យ

នស/រកត/០៦០៥/២៤៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់អោយប្រើជាផ្លូវការ នូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់តែងតាំង ប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចប្រធានព្រឹទ្ធសភា

ត្រាស់បង្គាប់

មាត្រា ១: ត្រូវបានបញ្ចប់មុខងារឯកឧត្តម ជា សួន ពីទីប្រឹក្សាផ្ទាល់សម្តេច ជា ស៊ីម ប្រធានព្រឹទ្ធសភា ដែលត្រូវបានទៅបំពេញភារកិច្ចថ្មី ជាសមាជិកព្រឹទ្ធសភាសំរាប់នីតិកាលទី ១ ។

មាត្រា ២: ប្រធានព្រឹទ្ធសភា និង នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៤៧-០៥០៦-២៦០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០០៥

លេខ : ៤២៨ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ាន់ គាន់

នស/រកត/០៦០៥/២៤៦

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣៩៩/០១ ចុះថ្ងៃទី ០៨ ខែ មិនា ឆ្នាំ ១៩៩៩ ដែលត្រាស់បង្គាប់អោយប្រើជាផ្លូវការនូវច្បាប់រដ្ឋធម្មនុញ្ញ ស្តីពីវិសោធនកម្មមាត្រា ១១ ១២ ១៣ ១៨ ២២ ២៤ ២៦ ២៨ ៣០ ៥១ ៩០ ៩១ ៩៣ និងមាត្រាទាំងឡាយនៃជំពូកទី ៨ ដល់ជំពូកទី ១៤ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ដែលរដ្ឋសភាបានអនុម័តនៅ ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ១៩៩៩
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៣៩៩/៤៣ ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ ១៩៩៩ ដែលត្រាស់ បង្គាប់តែងតាំងប្រធាន អនុប្រធានទី១ អនុប្រធានទី២ នៃព្រឹទ្ធសភា
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចប្រធានព្រឹទ្ធសភា

ត្រាស់បង្គាប់

មាត្រា១: តែងតាំងឯកឧត្តម **យ៉ា គឹមហួន** ជាទីប្រឹក្សារបស់អគ្គលេខាធិការព្រឹទ្ធសភា មានឋានៈស្មើ **អនុរដ្ឋលេខាធិការ** ដោយពុំទទួលប្រាក់បៀវត្ស ។

មាត្រា២: ប្រធានព្រឹទ្ធសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣: ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រស.០៥០៦.២៦១

លេខ : ៦២៦៩ ច.ល

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០០៥

ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

ណាំឌី តាន់

នស/រកត/០៦០៥/២៤៧

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្មហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំង ឯកឧត្តម សោម សារី ជាទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ រដ្ឋមន្ត្រី ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៥០៦.២៦២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១ ខែ មិថុនា ឆ្នាំ ២០០៥

លេខ: ៧៧៥ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ០១ ខែ មិថុនា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
ស៊ុំ ម៉ាទី តាន់

Chhor Phaly Created on 5-24-2005 9:07 AM

៧/២

ព្រះរាជក្រឹត្យ

នស/រកត/០៦០៥/២៥៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: តែងតាំង :

១- ឯកឧត្តម **គាត ឈន់** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាតំណាងពេញសិទ្ធិ ប្រចាំមជ្ឈមណ្ឌលអន្តរជាតិសំរាប់ដោះស្រាយវិវាទវិនិយោគ ។

២- ឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាតំណាងបំរុង ប្រចាំមជ្ឈមណ្ឌលអន្តរជាតិសំរាប់ដោះស្រាយវិវាទវិនិយោគ ។

មាត្រា ២: សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រស.០៥០៦.២៧២

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០០៥

លេខ: ៥៣៤ ច.ល
ដើម្បីចម្លងចែកជូន
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាវី តាន់

ព្រះរាជក្រឹត្យ

នស/រកត/០៦០៥/២៥៧

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងឯកឧត្តមចំនួន ០៣ រូប ជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ដូចមានរាយនាមខាងក្រោម :

១- ឯកឧត្តម **ម៉ា ឈឿន** ជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

២- ឯកឧត្តម **ចក់ ឡេង** ជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន

៣- ឯកឧត្តម **ឌុល គឿន** ជាទីប្រឹក្សាផ្ទាល់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា មានឋានៈស្មើ **រដ្ឋលេខាធិការ** បន្ថែមលើមុខងារបច្ចុប្បន្ន ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រស.០៥០៦.៧៧៣

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០០៥

លេខៈ [illegible] ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
[signature]
សូ ខាន់

CPL-2004

L/2

នស/រកត/០៦០៥/២៥៨

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម /១០៩៦/៣០ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីសញ្ជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ផ្តល់សញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម ដល់អ្នកស្រី **អាលីស គំប៉ាំង** (Alice COMPAIN) សញ្ជាតិដើម អង់គ្លេស កើតថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ១៩៣៤ នៅក្រុងឡុងដុង ប្រទេសអង់គ្លេស ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣/ណ.០៥០៦.២៧៤

ធ្វើនៅព្រះបរមរាជវាំង, រាជធានីភ្នំពេញ, ថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០០៥

លេខ ៥៣៧ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
ឡោអ៊ី តាន់

ព្រះរាជក្រឹត្យ

នស/រកត/០៦០៥/២៤៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា
សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា)

តែងតាំង

លោកស្រី ស៊ុយ សុផាន

ជា

ឧកញ៉ា

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រល.០៥០៦.២៧៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០០៥

លេខ : ៥៣៤ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាង តាន់

ព្រះរាជក្រឹត្យ

នស/រកត/០៦០៥/២៦០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៨៤ ចុះថ្ងៃទី ២៧ ខែ កញ្ញា ឆ្នាំ២០០៤ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ១២៩៧ / ៩១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តនៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០១០៥ / ០១៩ ចុះថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០៥ ស្តីពីការបង្កើតរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ។
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : តែងតាំងសមាសភាពថ្នាក់ដឹកនាំរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ដូចមានរាយនាមខាងក្រោម៖

១. **ឯកឧត្តម នេព ជាវ៉ុន** ជាប្រធាននៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

២. **ឯកឧត្តម កើត សេការណ្ឌ** ជាអគ្គលេខាធិការនៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ មានឋានៈស្មើ **អគ្គនាយក** ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ៕

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស/រកត/០៦០៥/២៧៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០០៥

លេខ: ៦៧៦ ច.ល

ដើម្បីចម្លងចេញ

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ២០០៥

អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាង ឆាន់

នស/រកត/០៦០៥/២៦១

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

(យោងតាមសេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃ រាជរដ្ឋាភិបាលកម្ពុជា)

ប្រោសព្រះរាជទាន

ជូន

ក-គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ ធិបឌិន្ទ :

-ឯកឧត្តម អ៊ឹម សូស្ថី

ខ-គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ សេនា :

-ឯកឧត្តម ម៉ៅ ឆាយលាង

គ-គ្រឿងឥស្សរិយយសព្រះរាជាណាចក្រកម្ពុជា ថ្នាក់ អស្សរឫទ្ធិ :

១-ឯកឧត្តម ម៉ាន សារិ
២-លោកជំទាវ កុយ ទើត
៣-លោកជំទាវ ស៊ុន ជុំមួ

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ : ៥៣៨ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ១០ ខែ មិថុនា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

៣រល.០៥០៦.២៧៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ,ថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០០៥

សោម គាន់

ព្រះរាជក្រឹត្យ

នស/រកត/០៦០៥/២៦២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានត្ថមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៩៩៥/៦៥ ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: ត្រូវបានតែងតាំងឯកឧត្តម ថាច់ ឃន ជាអនុប្រធាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន មានឋានៈស្មើ រដ្ឋមន្ត្រី ។

មាត្រា ២: រាល់បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣: សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រស-០៥០៦.២៧៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ មិថុនា ឆ្នាំ ២០០៥

លេខ: ៥៣៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
[illegible] តាន់

នស/រកត/០៦០៥/២៦៣

ព្រះរាជក្រឹត្យ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១: ត្រូវបានតែងតាំងឯកឧត្តម រ័ត្ន សណ្ដាប់ ជាអនុប្រធាន នៃអាជ្ញាធរជាតិទេសចរណ៍កម្ពុជា មានឋានៈស្មើ **រដ្ឋលេខាធិការ** ។

មាត្រា ២: រាល់បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣: សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៤: ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៖ល-០៥០៦.២៧៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ មិថុនា ឆ្នាំ ២០០៥

លេខ ៤៧១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
ណារី តាន់

ព្រះរាជក្រឹត្យ

នស/រកត/០៦០៥/២៦៤

យើង

ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ក្រឹត្យលេខ ២៨ក្រ ចុះថ្ងៃទី ២០ ខែ មិថុនា ឆ្នាំ ១៩៨៨ ស្តីពីការលើកលែងទោស និងបន្ធូរបន្ថយទោស
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ១២ ខែ ឱ្យទណ្ឌិតចំនួន ០៤ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមកដូចមានរាយឈ្មោះខាងក្រោមនេះ ÷

១-ទណ្ឌិតឈ្មោះ **ហ៊ើយ សារ៉េន** ភេទប្រុស អាយុ ២៦ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៣-៤-៩២ ពីបទឃាដកម្មគិតទុកជាមុន ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៣ ចុះថ្ងៃទី ២៨-៦-៩៣ របស់តុលាការខេត្តបាត់ដំបង ។

២-ទណ្ឌិតឈ្មោះ **សុខ ដឿន** ភេទប្រុស អាយុ ៣២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១១-៧-៩៥ ពីបទឃាដកម្មគិតទុកជាមុន ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣១ ចុះថ្ងៃទី ២១-៦-៩៥ របស់តុលាការក្រុងព្រះសីហនុ ។

៣-ទណ្ឌិតឈ្មោះ **ជឹប សុផល ហៅ ម៉ៅ** ភេទប្រុស អាយុ ៣៣ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ៧-៦-៩៦ ពីបទប្លន់ និងឃាដកម្មគិតទុកជាមុន ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ២០ឆ្នាំ តាមអំណាចសាលក្រមលេខ ០៧ ចុះថ្ងៃទី ១២-៦-៩៦ របស់តុលាការខេត្តស្ទឹងត្រែង ។

៤-ទណ្ឌិតឈ្មោះ **ព្រាំ មាន** ភេទប្រុស អាយុ ៣៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០១-៥-៩៧ ពីបទប្លន់ និងឃាតកម្មគិតទុកជាមុន ហើយត្រូវតុលាការសំរេចផ្ដន្ទាទោសដាក់ពន្ធនា គារកំណត់ ២០ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៨ ចុះថ្ងៃទី ២៤-១១-៩៧ របស់តុលាការខេត្តស្ទឹងត្រែង ។

មាត្រា ២ : ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ៩ ខែ ឱ្យទណ្ឌិតចំនួន ១០ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមកដូចមានរាយឈ្មោះខាងក្រោមនេះ ÷

១-ទណ្ឌិតឈ្មោះ **កែវ ភព** ភេទប្រុស អាយុ ២២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៣-៩-៩៨ ពីបទមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសំរេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ១១ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៤៦ ចុះថ្ងៃទី ០៩-១២-៩៦ របស់តុលាការខេត្តបាត់ដំបង ។

២-ទណ្ឌិតឈ្មោះ **សុខ និន** ភេទប្រុស អាយុ ៦៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៦-១០-៩៩ ពីបទមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសំរេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រមលេខ ៦៧ ចុះថ្ងៃទី ២៥-២-២០០០ របស់តុលាការខេត្តបាត់ដំបង ។

៣-ទណ្ឌិតឈ្មោះ **ឌឹម ភខ** ភេទប្រុស អាយុ ៣៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ៣០-១១-៩៨ ពីបទមនុស្សឃាតដោយចេតនា បទបង្ករបួសដោយចេតនាមានអាវុធ និងប្រើប្រាស់អាវុធជាតិផ្ទុះខុសច្បាប់ ហើយត្រូវតុលាការសំរេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ឆ្នាំ តាមអំណាចសាលក្រម លេខ ១២ ចុះថ្ងៃទី ២៦-០១-៩៩ របស់តុលាការខេត្តបាត់ដំបង ។

៤-ទណ្ឌិតឈ្មោះ **នីយ សឿម** ភេទប្រុស អាយុ ៣៣ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៦-១២-៩៥ ពីបទប៉ុនប៉ងរំលោភសេពសន្ថវៈ និងបទមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសំរេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ១២ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៣ ចុះថ្ងៃទី ២២-៤-៩៦ របស់តុលាការខេត្តបាត់ដំបង ។

៥-ទណ្ឌិតឈ្មោះ **ខៀវ កុម្ភៈ** ភេទប្រុស អាយុ ១៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២០-០២-២០០១ ពីបទប្លន់ និងប៉ុនប៉ងធ្វើមនុស្សឃាត ហើយត្រូវតុលាការសំរេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាច សាលក្រមលេខ ០១ ចុះថ្ងៃទី ២៨-០១-២០០២ របស់តុលាការខេត្តស្ទឹងត្រែង ។

៦-ទណ្ឌិតឈ្មោះ **សួង ខាន់** ភេទប្រុស អាយុ ២២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២០-០២-២០០១ ពីបទប្លន់ និងប៉ុនប៉ងធ្វើមនុស្សឃាត ហើយត្រូវតុលាការសំរេចផ្ដន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ០១ ចុះថ្ងៃទី ២៨-០១-២០០២ របស់តុលាការខេត្តស្ទឹងត្រែង ។

៧-ទណ្ឌិតឈ្មោះ **អ៊ុត ធឿន** ភេទប្រុស អាយុ ២៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៧-៩-២០០០ ពីបទឃាតកម្មគិតទុកជាមុន និងប្រើប្រាស់អាវុធខុសច្បាប់ ហើយត្រូវតុលាការសំរេចផ្ដន្ទាទោស

ដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៩ ចុះថ្ងៃទី ១៦-៥-២០០១ របស់តុលាការខេត្តស្ទឹងត្រែង ។

៨-ទណ្ឌិតឈ្មោះ **អ៊ូ ពេជ្រ** ភេទប្រុស អាយុ ២៣ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ១៧-១២-៩៨ ពីបទ ភេរវកម្ម ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលដីកា ៣៣"ខ" ចុះថ្ងៃទី ១៤-៥-២០០៣ របស់សាលាឧទ្ធរណ៍ ។

៩-ទណ្ឌិតឈ្មោះ **គីម ស៊ីណា ហៅ ស្លា** ភេទប្រុស អាយុ ២៣ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២២-៥-៩៧ ពីបទរំលោភសេពសន្ថវៈ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៤"ក" ចុះថ្ងៃទី ២៤-១១-៩៧ របស់តុលាការក្រុងភ្នំពេញ ។

១០-ទណ្ឌិតឈ្មោះ **ស៊ុន ម៉ានីន** ភេទប្រុស អាយុ ៣០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៣-០២-៩៩ ពីបទភេរវកម្ម ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៧"ដ" ចុះថ្ងៃទី ០៣-១០-២០០០ របស់តុលាការក្រុងភ្នំពេញ ។

មាត្រា ៣ : ត្រូវបន្ថយរយៈពេលទទួលរងទោសចំនួន ៦ ខែ ឱ្យទណ្ឌិតចំនួន ២០ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមកដូចមានរាយឈ្មោះខាងក្រោមនេះ ÷

១-ទណ្ឌិតឈ្មោះ **ឆៅ សុផល** ភេទប្រុស អាយុ ៣៣ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៩-៣-២០០១ ពីបទជួញដូរគ្រឿងញៀនដោយខុសច្បាប់ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៤"ខ" ចុះថ្ងៃទី ០៥-៦-២០០១ របស់តុលាការខេត្តបាត់ដំបង ។

២-ទណ្ឌិតឈ្មោះ **សាំ សឿត** ភេទប្រុស អាយុ ៣៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០២-០១-២០០០ ពីបទប៉ុនប៉ងធ្វើមនុស្សឃាដដោយចេតនា ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៤៥ ចុះថ្ងៃទី ២៨-៦-៩៩ របស់តុលាការខេត្តបាត់ដំបង ។

៣-ទណ្ឌិតឈ្មោះ **សឿន សល់** ភេទប្រុស អាយុ ២៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២២-៦-២០០០ ពីបទក្រុមជនប្រដាប់អាវុធ និងប្លន់ទ្រព្យសម្បត្តិប្រជារាស្ត្រ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ឆ្នាំ តាមអំណាចសាលក្រមលេខ ២៤៤ ចុះថ្ងៃទី ២៨-៩-៩៩ របស់តុលាការខេត្តបាត់ដំបង ។

៤-ទណ្ឌិតឈ្មោះ **ចិញ សារ៉េត** ភេទស្រី អាយុ ៣៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៥-៩-២០០០ ពីបទបង្ករបួសដោយចេតនាមានអាវុធ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ១២"ក" ចុះថ្ងៃទី ២៥-០១-២០០១ របស់តុលាការខេត្តបាត់ដំបង ។

៥-ទណ្ឌិតឈ្មោះ **លន់ លីន** ភេទស្រី អាយុ ១៥ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៦-៨-២០០០ ពីបទមនុស្សឃាតដោយចេតនា និងប្លន់ទ្រព្យសម្បត្តិប្រជារាស្ត្រ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៦៩ ចុះថ្ងៃទី ១៤-១១-២០០០ របស់តុលាការខេត្តបាត់ដំបង ។

៦-ទណ្ឌិតឈ្មោះ **ម៉ាត តឿ** ភេទស្រី អាយុ ២៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៧-០១-៩៩ ពីបទពង្រត់មនុស្សទៅលក់ធ្វើពេស្យាចារ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៨៩ ចុះថ្ងៃទី ២៧-៧-៩៩ របស់តុលាការខេត្តបាត់ដំបង ។

៧-ទណ្ឌិតឈ្មោះ **ម៉ៅញ ទាំ** ភេទប្រុស អាយុ ៣៧ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ៣០-៥-២០០០ ពីបទមនុស្សឃាតដោយចេតនា ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៤៣ ចុះថ្ងៃទី ២៤-១០-២០០០ របស់តុលាការខេត្តបាត់ដំបង ។

៨-ទណ្ឌិតឈ្មោះ **ឆួន សុធី ហៅ សល់** ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៦-៣-២០០១ ពីបទរំលោភសេពសន្ថវៈ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ៣៥"ឈ" ចុះថ្ងៃទី ១០-៥-២០០១ របស់តុលាការខេត្តបាត់ដំបង ។

៩-ទណ្ឌិតឈ្មោះ **យ៉ន យ៉េង** ភេទប្រុស អាយុ ៣៣ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៤-១១-២០០២ ពីបទរំលោភលើសេចក្តីទុកចិត្ត ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តែ ទោសនេះត្រូវព្យួរចំនួនមួយឆ្នាំរយៈពេលសាកល្បង ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១៩"ខ" ចុះថ្ងៃទី ២៥-៣-២០០៣ របស់តុលាការខេត្តបាត់ដំបង ។

១០-ទណ្ឌិតឈ្មោះ **នឹម សុខា** ភេទប្រុស អាយុ ៤០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៦-១២-៩៩ ពីបទ ប្លន់ទ្រព្យសម្បត្តិប្រជារាស្ត្រ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលដីកាលេខ ៣០ "ខ" ចុះថ្ងៃទី ២៥-១២-២០០២ របស់សាលាឧទ្ធរណ៍ ។

១១-ទណ្ឌិតឈ្មោះ **យឹម ផល្លី** ភេទប្រុស អាយុ ២៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៩-១២-២០០០ ពីបទប៉ុនប៉ងធ្វើឃាត ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៦ ឆ្នាំ តាមអំណាចសាលក្រមលេខ ២៥ ចុះថ្ងៃទី ២៥-៦-២០០១ របស់តុលាការខេត្តស្ទឹងត្រែង ។

១២-ទណ្ឌិតឈ្មោះ **ទ៉ាន់ឌី ខាំផែ** ភេទប្រុស អាយុ ២១ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៤-០១-២០០២ ពីបទប្លន់ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៤ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៤ ចុះថ្ងៃទី ០៤-៤-២០០២ របស់តុលាការខេត្តស្ទឹងត្រែង ។

១៣-ទណ្ឌិតឈ្មោះ **នួន ពៅរ័ត្ន** ភេទប្រុស អាយុ ២៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៦-១០-២០០២ ពីបទប្លន់ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១២ ចុះថ្ងៃទី ១១-០២-២០០៣ របស់តុលាការខេត្តក្រចេះ ។

១៤-ទណ្ឌិតឈ្មោះ **នួន សុរិយា** ភេទប្រុស អាយុ ១៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៦-១០-២០០២ ពីបទប្លន់ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១២ ចុះថ្ងៃទី ១១-០២-២០០៣ របស់តុលាការខេត្តក្រចេះ ។

១៥-ទណ្ឌិតឈ្មោះ **កែវ ធឿន** ភេទប្រុស អាយុ ១៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ១៦-១០-២០០២ ពីបទប្លន់ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ១២ ចុះថ្ងៃទី ១១-០២-២០០៣ របស់តុលាការខេត្តក្រចេះ ។

១៦-ទណ្ឌិតឈ្មោះ **មឿន ខ្លី** ភេទប្រុស អាយុ ២៣ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៥-៧-២០០៣ ពីបទប្លន់ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំតាមអំណាចសាលក្រមលេខ ០៥ ចុះថ្ងៃទី ១៥-០១-២០០៤ របស់តុលាការខេត្តក្រចេះ ។

១៧-ទណ្ឌិតឈ្មោះ **ខ្លួន ភួន** ភេទប្រុស អាយុ ២៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៥-៧-២០០៣ ពីបទប្លន់ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ០៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៥ ចុះថ្ងៃទី ១៥-០១-២០០៤ របស់តុលាការខេត្តក្រចេះ ។

១៨-ទណ្ឌិតឈ្មោះ **ហួត ថាវរៈ ហៅ ហួច** ភេទប្រុស អាយុ ២៩ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី២៩-០២-២០០៣ ពីបទបង្ករបួសដោយចេតនា ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ០៨ ចុះថ្ងៃទី ២០-០១-២០០៤ របស់តុលាការខេត្តក្រចេះ ។

១៩-ទណ្ឌិតឈ្មោះ **ហៃ សុខី** ភេទប្រុស អាយុ ១៨ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២២-០១-២០០៣ ពីបទប្លន់ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ តាមអំណាចសាលក្រមលេខ ៤១ ចុះថ្ងៃទី ០៨-៧-២០០៣ របស់តុលាការខេត្តក្រចេះ ។

២០-ទណ្ឌិតឈ្មោះ **ហ្វាម ធីខាំ** ភេទស្រី អាយុ ៣២ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៣-០១-៩៨ ពីបទជួញដូរគ្រឿងញៀនខុសច្បាប់ ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៨ ឆ្នាំ តាមអំណាចសាលដីកាលេខ ៣១ ចុះថ្ងៃទី ៣១-៣-២០០៤ របស់តុលាការកំពូល ។

មាត្រា ៤ : ត្រូវលើកលែងទោសឱ្យទណ្ឌិតចំនួន ០៣ នាក់ ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមកដូចមានរាយឈ្មោះខាងក្រោមនេះ ÷

១-ទណ្ឌិតឈ្មោះ ឈ្មោះ ញ៉េម ហ៊ាន ភេទប្រុស អាយុ ២៤ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ២៥-១១-២០០២ ពីបទបៀតបៀនកេរ្តិ៍ខ្មាស់ និងបង្ករបួសដោយចេតនា ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ៣ ឆ្នាំ តាមអំណាចសាលក្រមលេខ ០៣ ចុះថ្ងៃទី ១០-០២-២០០២ របស់តុលាការខេត្តស្ទឹងត្រែង ។

២-ទណ្ឌិតឈ្មោះ នាង ម៉ៅ ភេទប្រុស អាយុ ២០ ឆ្នាំ ត្រូវចាប់ខ្លួននៅថ្ងៃទី ០៧-១១-៨៦ ពីបទរំលោភសេពសន្ថវៈ និងឃាតកម្ម ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត តាមអំណាចសាលក្រមលេខ ០៤ ចុះថ្ងៃទី ២៧-៧-៨៧ របស់តុលាការក្រុងព្រះសីហនុ ។

៣-ទណ្ឌិតឈ្មោះ ប្រាក់ ម៉ុនហៀង ភេទប្រុស អាយុ ២៣ ឆ្នាំ ត្រូវឃុំខ្លួននៅថ្ងៃទី ២១-១២-៩៨ ពីបទភេរវកម្ម ហើយត្រូវតុលាការសំរេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលដីកាលេខ ៣៣"ខ" ចុះថ្ងៃទី ១៤-៥-២០០៣ របស់សាលាឧទ្ធរណ៍ ។

មាត្រា ៥ : សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាត្រូវអនុវត្តឱ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៦ : ព្រះរាជក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស/រកត.០៥០៦.២៨០

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ មិថុនា ឆ្នាំ ២០០៥

បានឃើញ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

សាខ តាន់

ព្រះរាជក្រឹត្យ

នស/រកត/០៦០៥/២៦៩

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៣ នៃរដ្ឋសភា នាថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ និងថ្នាក់ដឹកនាំរដ្ឋសភា និងសំដែងការទុកចិត្ត ទៅលើសមាភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចក្រុមព្រះ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១.- តែងតាំងឯកឧត្តម **ម៉ម ប៊ុននាង** ជាទីប្រឹក្សាផ្ទាល់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី៣ មានឋានៈស្មើ **រដ្ឋមន្ត្រី** ដោយពុំទទួលប្រាក់បៀវត្ស។

មាត្រា ២.- ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះឱ្យបានសំរេច ។

មាត្រា ៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣ល.០៥០៦.២៨៥

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ២០០៥

លេខ ៥៧៤១ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
ណាឌី តាន់

ព្រះរាជក្រឹត្យ

នស/រកត/០៦០៥/២៧០

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៣ នៃរដ្ឋសភា នាថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ និងថ្នាក់ដឹកនាំរដ្ឋសភា និងសំដែងការទុកចិត្ត ទៅលើសមាភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចក្រុមព្រះ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១.-តែងតាំងឯកឧត្តម ឧត្តមសេនីយ៍ត្រី គង់ ចន្ធី ជាទីប្រឹក្សាផ្ទាល់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ព្រះប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី៣ មានឋានៈស្មើ រដ្ឋលេខាធិការ ដោយពុំទទួលប្រាក់បៀវត្ស ។

មាត្រា ២.-ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះឱ្យបានសំរេច ។

មាត្រា ៣ .-ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រស.០៥០៦.២៨៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ២០០៥

លេខ ២៤០ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

សាន់ គាន់

ព្រះរាជក្រឹត្យ

នស/រកត/០៦០៥/២៧១

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៣ នៃរដ្ឋសភា នាថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ និងថ្នាក់ដឹកនាំរដ្ឋសភា និងសំដែងការទុកចិត្ត ទៅលើសមាភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចក្រុមព្រះ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១.- តែងតាំងឯកឧត្តម **ខឹន នាង** ជាទីប្រឹក្សាផ្ទាល់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី៣ មានឋានៈស្មើ **រដ្ឋលេខាធិការ** ដោយពុំទទួលប្រាក់បៀវត្ស ។

មាត្រា ២.- ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះឱ្យបានសំរេច ។

មាត្រា ៣ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣រស-០៥០៦.២៨៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ២០០៥

ដើម្បីចម្លងចេញ
រាជធានីភ្នំពេញ ថ្ងៃទី១៨ ខែមិថុនា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈានី តាន់

ព្រះរាជក្រឹត្យ

នស/រកត/០៦០៥/២៧២

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានទ្រង់យល់បទបញ្ជាផ្ទៃក្នុងរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់លទ្ធផលនៃសម័យប្រជុំលើកទី១ នីតិកាលទី៣ នៃរដ្ឋសភា នាថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការជ្រើសតាំងរចនាសម្ព័ន្ធ និងថ្នាក់ដឹកនាំរដ្ឋសភា និងសំដែងការទុកចិត្ត ទៅលើសមាភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចក្រុមព្រះ ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១.-តែងតាំងឯកឧត្តម **ឃ្លាំង ហួត** ជាទីប្រឹក្សាផ្ទាល់សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** ព្រះប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា នីតិកាលទី៣ មានឋានៈស្មើ **រដ្ឋលេខាធិការ** ដោយពុំទទួលប្រាក់បៀវត្ស ។

មាត្រា ២.-ប្រធានរដ្ឋសភា និងនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះឱ្យបានសំរេច ។

មាត្រា ៣.-ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះ តទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣៧ល.០៥០៦.២៥៤

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ ២០០៥

ច.ល
ដើម្បីចម្លងចេញ
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

ឈាឌី តាន់

ព្រះរាជក្រឹត្យ

នស/រកត/០៦០៥/២៧៥

យើង

ព្រះករុណាព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

-បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៤៩៦/២៥ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតអាជ្ញាធរជាតិទទួលបន្ទុកដោះស្រាយកិច្ចការព្រំដែន

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រាមួយ : ត្រូវបានកែសម្រួលមាត្រា១ មាត្រា២ មាត្រា៣ មាត្រា៤ មាត្រា៥ និងមាត្រា៦ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៦/២៥ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៦ ដែលមានខ្លឹមសារដូចតទៅ :

មាត្រា១ថ្មី : បង្កើតអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ដែលមានសមាសភាពដូចតទៅ :

១-នាយករដ្ឋមន្ត្រី	ប្រធាន
២-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី	អនុប្រធានអចិន្ត្រៃយ៍
៣-រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	អនុប្រធាន

៤-សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អនុប្រធាន
៥-សហរដ្ឋមន្ត្រីក្រសួងការពារជាតិ អនុប្រធាន
៦-រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
៧-រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ សមាជិក
៨-ឯកឧត្តម វ៉ា គឹមហុង ទីប្រឹក្សារាជរដ្ឋាភិបាលទទួលបន្ទុកកិច្ចការព្រំដែន សមាជិក
និងជាប្រធានលេខាធិការដ្ឋានអចិន្ត្រៃយ៍មានឋានៈស្មើទេសរដ្ឋមន្ត្រី
៩-ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស សមាជិក
១០-អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ សមាជិក

មាត្រា២ថ្មី : អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន មានភារកិច្ច :

-រៀបចំ និងកសាងលិខិតបទដ្ឋានមានលក្ខណៈច្បាប់ ស្តីពីការកំណត់ព្រំដែនដីគោក និងព្រំដែនសមុទ្រ ដើម្បីយកទៅតម្កល់នៅទីស្នាក់ការអង្គការសហប្រជាជាតិ ។

-សិក្សា ស្រាវជ្រាវ ឱ្យបានហ្មត់ចត់បំផុត ក្នុងការជ្រើសរើសយកផែនទីសម្រាប់ធ្វើការកំណត់ខ្សែបន្ទាត់ព្រំដែនដីគោក និងព្រំដែនសមុទ្រឱ្យបានច្បាស់លាស់រវាងព្រះរាជាណាចក្រកម្ពុជា ជាមួយប្រទេសជិតខាង ។

-ធ្វើការចរចា សម្របសម្រួល ដោះស្រាយ និងសម្រេចលើបញ្ហាព្រំដែនជាមួយប្រទេសជិតខាង លើរាល់កិច្ចការដែលមានទំនាក់ទំនងលើការងារព្រំដែន ក្រោយពីមានការឯកភាពពីរាជរដ្ឋាភិបាល ។

-លើកគំរោងអភិវឌ្ឍន៍តំបន់ព្រំដែន ជូនរាជរដ្ឋាភិបាលពិនិត្យ និងសម្រេច ។

-ប្រធានអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន មានសិទ្ធិចុះហត្ថលេខាលើសន្ធិសញ្ញាស្តីពីបញ្ហាព្រំដែន ជាមួយប្រទេសជិតខាង ។

-ធ្វើរបាយការណ៍តាមដំណាក់កាលនីមួយៗ អំពីសកម្មភាពរបស់ខ្លួន ជូនក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទទួលបន្ទុកកិច្ចការព្រំដែន ។

មាត្រា៣ថ្មី : អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន មានយន្តការពីរ ជាសេនាធិការ :

<u>យន្តការទី១</u> : ជាគណៈកម្មាធិការនីតិកម្មនិងបច្ចេកទេសកិច្ចការព្រំដែន ដែលមានភារកិច្ចៈ

-សិក្សា ស្រាវជ្រាវ ដើម្បីរៀបចំឯកសារជាលក្ខណៈច្បាប់ ទាំងព្រំដែនគោក ទាំងព្រំដែនសមុទ្រជាមួយប្រទេសជិតខាង ធ្វើជាមូលដ្ឋានបង្អែកសម្រាប់ពិភាក្សាជាមួយប្រទេសជិតខាង។

-ធ្វើការចរចាជាមួយប្រទេសជិតខាង ក្នុងការកំណត់ជ្រើសរើសយកផែនទីសម្រាប់ធ្វើការវាស់វែងខ្សែបន្ទាត់ព្រំដែន ។

-ចុះធ្វើការវាស់វែង កំណត់ខ្សែបន្ទាត់ព្រំដែន ខណ្ឌព្រំសីមា និងបោះបង្គោលព្រំដែនរវាងព្រះរាជាណាចក្រកម្ពុជា ជាមួយប្រទេសជិតខាង ។

-ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ខ្លួនតាមការកំណត់ ផ្ញើជូនអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ។

សមាសភាពនៃគណៈកម្មាធិការនេះ កំណត់ដោយអនុក្រឹត្យ ។

យន្តការទី២ : ជាគណៈកម្មាធិការត្រួតពិនិត្យ ដោះស្រាយបាតុភាព និងអភិវឌ្ឍន៍នៅតាមបណ្តោយព្រំដែនជាមួយប្រទេសជិតខាង ដែលមានភារកិច្ច:

-ត្រួតពិនិត្យកិច្ចការការពារខ្សែបន្ទាត់ព្រំដែន នៃព្រះរាជាណាចក្រកម្ពុជា ។

-ធ្វើអន្តរាគមន៍ដោះស្រាយចំពោះបាតុភាព ឬទំនាស់ព្រំដែនជាមួយខេត្តជាប់ព្រំដែន របស់ប្រទេសជិតខាង តាមស្មារតីនៃលទ្ធផលស្តីពីដំណោះស្រាយបញ្ហាព្រំដែន ដែលទទួលបានពីអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ។

-ចូលរួមជាមួយគណៈកម្មាធិការនីតិកម្ម និងបច្ចេកទេស ក្នុងការចរចាដោះស្រាយបញ្ហាព្រំដែន ជាមួយប្រទេសជិតខាងតាមការចាំបាច់ ។

-លើកគំរោងអភិវឌ្ឍន៍តំបន់ព្រំដែន ជូនអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ។

-ធ្វើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់ខ្លួនតាមការកំណត់ ផ្ញើជូនអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ។

សមាសភាពនៃគណៈកម្មាធិការនេះ កំណត់ដោយអនុក្រឹត្យ ។

មាត្រា៤ថ្មី : យន្តការទាំងពីរនេះ មានលេខាធិការដ្ឋានរួមមួយ នៅទីស្តីការគណៈរដ្ឋមន្ត្រី ហៅថា : លេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ដែលមាន :

-ឯកឧត្តម **វ៉ា គឹមហុង** ប្រធាន

-ឯកឧត្តម **ហួន សាវ៉ាង** អនុប្រធាន

មានឋានៈស្មើអនុរដ្ឋលេខាធិការបន្ថែមលើមុខងារបច្ចុប្បន្ន

-លោកជំទាវ **កុយ ពិសី** លេខាធិការ

មានឋានៈស្មើអគ្គនាយក

-ប្រធាន នាយកដ្ឋានភូមិសាស្ត្រ សមាជិក

-ប្រធាន នាយកដ្ឋានសុរិយោដី សមាជិក

-មន្ត្រីជំនាញមួយចំនួន តាមសេចក្តីត្រូវការជាក់ស្តែង

លេខាធិការដ្ឋាននេះ ជាអ្នកសម្របសម្រួលកិច្ចការរវាងគណៈកម្មាធិការនីតិកម្ម និងបច្ចេកទេសស្តីពីកិច្ចការព្រំដែន និងគណៈកម្មាធិការត្រួតពិនិត្យ ដោះស្រាយបាតុភាព និងអភិវឌ្ឍន៍នៅតាមបណ្តោយខ្សែព្រំដែនជាមួយប្រទេសជិតខាង ហើយជាក្បាលម៉ាស៊ីនរដ្ឋបាល និងជាហិរញ្ញកិច្ចរបស់អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ដោយប្រើប្រាស់មន្ត្រីរបស់ទីស្តីការគណៈរដ្ឋមន្ត្រី មន្ត្រីរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (នាយកដ្ឋានភូមិសាស្ត្រ និងនាយកដ្ឋានសុរិយោដី) និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ សម្រាប់ជំនួយការ ។

លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

លេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ត្រូវកសាងផែនការចំណាយរបស់អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ។

មាត្រា៥ថ្មី : លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន មានភារកិច្ច :

-សិក្សាស្រាវជ្រាវនិងស្វែងយល់បន្ថែមលើការងារបច្ចេកទេស ដែលពាក់ព័ន្ធនឹងបញ្ហាព្រំដែន ដើម្បីរៀបចំ និងកសាងឱ្យបានលិខិតបទដ្ឋានមានលក្ខណៈច្បាប់សម្រាប់យកទៅដាក់ជូនអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ។

-ចុះពិនិត្យ និងធ្វើការវាស់វែងដល់ទីកន្លែងកើតហេតុ និងបាតុភាពនានាតាមបណ្តោយព្រំដែន រួចរាយការណ៍ជូនអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ដើម្បីពិនិត្យ និងសម្រេច។

-ចូលរួមក្នុងការចរចាជាមួយប្រទេសជិតខាង ដើម្បីកំណត់ជ្រើសរើសយកផែនទីសម្រាប់ធ្វើជាមូលដ្ឋានក្នុងការដោះស្រាយបញ្ហាបច្ចេកទេសឱ្យបានត្រឹមត្រូវច្បាស់លាស់ ។

-លើកគម្រោងអភិវឌ្ឍន៍តំបន់ព្រំដែន ដាក់ជូនអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ដើម្បីពិនិត្យ និងសម្រេច ។

-សហការជាមួយអភិបាល ឬអភិបាលរងខេត្ត ក្រុង ដែលនៅជាប់ព្រំដែនជាមួយប្រទេសជិតខាងក្នុងការសិក្សាស្រាវជ្រាវលើទីតាំងបង្គោលសីមាព្រំដែន និងខ្សែបន្ទាត់ព្រំដែនជាក់ស្តែងទៅនឹងបញ្ហាបច្ចេកទេសជំនាញ រួចរាយការណ៍អំពីលទ្ធផលជូនអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ។

-ធ្វើរបាយការណ៍តាមការកំណត់ អំពីសភាពការណ៍នៃការដោះស្រាយ និងការកំណត់ព្រំដែនជាមួយប្រទេសជិតខាងជូនអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន សម្រាប់រាយការណ៍ជូនរាជរដ្ឋាភិបាល ថ្នាក់ និងជូនក្រុមប្រឹក្សាជាតិជាន់ខ្ពស់ទទួលបន្ទុកកិច្ចការព្រំដែន ។

មាត្រា៦ថ្មី : អាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈ-រដ្ឋមន្ត្រី សម្របសម្រួលការងារ ។ សមាជិកអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

មាត្រាពីរ : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រាបី : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តឱ្យបានសម្រេចនូវព្រះរាជ-ក្រឹត្យនេះ ។

មាត្រាបួន : ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្ថលេខានេះតទៅ ។

ព្រះហស្ថលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

នស/រកត.០៦០៥.២៩១

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ២០០៥

លេខ : ៣៤៣ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
សាន់ តាន់

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ.....៧១.....អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការគ្រប់គ្រងសហគមន៍នេសាទ

*****

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៥/២៤០ ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៥ ស្តីពីការបង្កើតសហគមន៍នេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០០ អនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០១ អនុក្រឹត្យលេខ ០៦ អនក្រ.បក លេខ ០៧ អនក្រ.បក លេខ ០៨ អនក្រ.បក លេខ ០៩ អនក្រ.បក លេខ ១០ អនក្រ.បក ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០០១ អនុក្រឹត្យលេខ ១៩ អនក្រ.បក លេខ ២១ អនក្រ.បក លេខ ២២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០០១ អនុក្រឹត្យលេខ ២៣

អនក្រ.បក ចុះថ្ងៃទី១៩ ខែ កុម្ភៈ ឆ្នាំ ២០០១ អនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី ០៥ ខែ មីនា ឆ្នាំ ២០០១ អនុក្រឹត្យលេខ ៣០ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០០១ និងអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ស្តីពីការលុបនាទីឡូត៍នេសាទ និងការកាត់បន្ថយដែននេសាទក្នុងនាទីឡូត៍នេសាទក្នុងខេត្តបាត់ដំបង ខេត្តកំពង់ធំ ខេត្តកណ្តាល ខេត្តកំពង់ឆ្នាំង ខេត្តពោធិសាត់ ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ ខេត្តកំពង់ចាម រាជធានីភ្នំពេញ ខេត្តក្រចេះ ខេត្តព្រៃវែង និងខេត្តតាកែវ ទុកសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ

- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០០៥

សម្រេច

ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

មាត្រា ១.—

អនុក្រឹត្យនេះមានវិសាលភាព និងគោលដៅកំណត់អំពីវិធាន និងនីតិវិធីដើម្បីបង្កើត និងគ្រប់គ្រងសហគមន៍នេសាទនៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

មាត្រា ២.—

អនុក្រឹត្យនេះមានគោលបំណង ÷

- គ្រប់គ្រងដែននេសាទទឹកសាបដែលបានលុប ឬកាត់បន្ថយពីនាទីឡូត៍នេសាទ និងដែននេសាទដែលត្រូវការពារនាទីព្រៃលិចទឹក និងព្រៃកោងកាង និងដែននេសាទសមុទ្រ
- គ្រប់គ្រងធនធានជលផលប្រកបដោយចីរភាព និងធានាការបែងចែកផលប្រយោជន៍ពីធនធានជលផលជូនប្រជាពលរដ្ឋខ្មែរប្រកបដោយសមធម៌
- ដើម្បីឱ្យប្រជាពលរដ្ឋខ្មែរបានយល់ដឹង និងទទួលស្គាល់កាន់តែច្បាស់ឡើងនូវផលប្រយោជន៍ និងសារៈសំខាន់នៃធនធានជលផលតាមរយៈការចូលរួមគ្រប់គ្រង ប្រើប្រាស់ និងការពារធនធានជលផលដោយផ្ទាល់
- ផ្តល់ក្របខ័ណ្ឌច្បាប់សម្រាប់បង្កភាពងាយស្រួលជូនដល់ប្រជាពលរដ្ឋខ្មែរនៅតាមមូលដ្ឋានក្នុងការបង្កើតសហគមន៍នេសាទ
- លើកស្ទួយកម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋខ្មែរដើម្បីរួមចំណែកកាត់បន្ថយភាពក្រីក្រ។

មាត្រា ៣.—

កន្លែងនេសាទសហគមន៍គឺជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ។

ព្រំប្រទល់កន្លែងនេសាទសហគមន៍នីមួយៗត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

មាត្រា ៤.—

សិទ្ធិអំណាចដឹកនាំ និងគ្រប់គ្រងសហគមន៍នេសាទបានមកពីការបោះឆ្នោតរបស់សមាជិកសហគមន៍។

មាត្រា ៥.—

វាក្យស័ព្ទសំខាន់ៗ ដែលប្រើប្រាស់សម្រាប់អនុក្រឹត្យនេះត្រូវបានកំណត់ក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

ជំពូកទី ២
ការបង្កើតសហគមន៍នេសាទ

មាត្រា ៦.—

សហគមន៍នេសាទដែលចែងក្នុងអនុក្រឹត្យនេះ ជារូបវន្តបុគ្គលមួយក្រុមមានសញ្ជាតិខ្មែរ ដែលរស់នៅក្នុង ឬទីជិតខាងនៃដែននេសាទ ដែលត្រូវបានបង្កើតឡើងដោយការស្ម័គ្រចិត្ត និងមានគំនិតដូចផ្តើមបង្កើនជីវភាពរស់នៅរបស់ខ្លួនតាមរយៈការប្រើប្រាស់ និងកែច្នៃធនធានជលផលប្រកបដោយចីរភាពដើម្បីរួមចំណែកលើកតម្កើងសេដ្ឋកិច្ច សង្គមកិច្ច និងកាត់បន្ថយភាពក្រីក្រ។

នាយកដ្ឋានជលផល ការិយាល័យជលផលខេត្ត ក្រុង មន្ទីរកសិកម្មខេត្ត ក្រុង អាជ្ញាធរមូលដ្ឋាន ឬក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវរួមសហការរៀបចំបង្កើតសហគមន៍នេសាទ។

មាត្រា ៧.—

សហគមន៍នេសាទត្រូវមានលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង ផែនការគ្រប់គ្រង ផែនទីកន្លែងនេសាទសហគមន៍របស់ខ្លួន និងកិច្ចព្រមព្រៀងដែលមានការទទួលស្គាល់ពីអាជ្ញាធរមានសមត្ថកិច្ចស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

មាត្រា ៨.—

លក្ខន្តិកៈសហគមន៍នេសាទត្រូវបញ្ជាក់ពីនិទ្ទេសដូចតទៅ ÷

- នាមករណ៍
- ទីស្នាក់ការ និងអាសយដ្ឋាន
- កម្មវត្ថុ
- លក្ខខណ្ឌនៃការសុំចូលជាសមាជិក
- ភារកិច្ច និងសិទ្ធិរបស់សមាជិក
- លក្ខណៈវិនិច្ឆ័យ លក្ខខណ្ឌនៃការលាឈប់ និងការបណ្តេញចេញនៃសមាជិក
- របៀបរបបនៃការកាន់បញ្ជី និងឯកសារនានា
- សមាសភាពនៃគណៈកម្មការសហគមន៍នេសាទ
- លក្ខខណ្ឌនៃការកោះប្រជុំមហាសន្និបាត និងគណៈកម្មការសហគមន៍នេសាទ
- លក្ខខណ្ឌនៃការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ
- លក្ខខណ្ឌនៃការបែងចែកផលប្រយោជន៍ កម្រៃពីការធ្វើសេដ្ឋកិច្ចសមូហភាព បើសិនជាមាន
- លក្ខខណ្ឌនៃការរំលាយសហគមន៍នេសាទ
- នីតិវិធីនៃការកែប្រែលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ។

ជំពូកទី ៣

តួនាទី ភារកិច្ច និងសិទ្ធិរបស់សហគមន៍នេសាទ

មាត្រា ៩.—

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានបំណងចូលជាសមាជិកសហគមន៍នេសាទ ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម ÷

- មានលំនៅដ្ឋាននៅក្នុងបណ្តាភូមិនៃសហគមន៍នេសាទ
- មានសញ្ជាតិខ្មែរ
- មានអាយុចាប់ពី ១៨ ឆ្នាំឡើង ។ បុគ្គលម្នាក់អាចជាសមាជិកសហគមន៍នេសាទតែមួយគត់នៃសហគមន៍ដែលខ្លួនរស់នៅ ។

មាត្រា ១០.—

តួនាទី និងភារកិច្ចរបស់សហគមន៍នេសាទ ÷

- ចូលរួមគ្រប់គ្រង អភិរក្សធនធានជលផលស្របតាមលក្ខន្តិកៈ ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ស្រប ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងវិស័យជលផល
- គោរពតាមការណែនាំរបស់នាយកដ្ឋានជលផល និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ចូលរួមបង្កើតកន្លែងអភិរក្សក្នុងកន្លែងនេសាទសហគមន៍ ថែរក្សាការពារ និងដាំដុះព្រៃលិចទឹក និងព្រៃកោងកាង ស្តារព្រែក បឹងដែលរីងរាក់ដើម្បីកែលំអប្រព័ន្ធអេកូឡូស៊ី និងបរិស្ថានជលផលឡើងវិញ
- ធានាឱ្យសមាជិកទាំងអស់ក្នុងសហគមន៍នេសាទមានសិទ្ធិស្មើគ្នាលើការប្រើប្រាស់ធនធានជលផលប្រកបដោយ ចីរភាពដូចមានចែងក្នុងលក្ខន្តិកៈ
- អនុវត្តលក្ខន្តិកៈសហគមន៍នេសាទ និងធ្វើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- ចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ជាមួយនាយកដ្ឋានជលផលដើម្បីគ្រប់គ្រងធនធានជលផលប្រកប ដោយចីរភាព
- រក្សាទុកឯកសារទាំងឡាយដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ។

មាត្រា ១១.—

សិទ្ធិរបស់សហគមន៍នេសាទ ÷

- ចាត់ចែងការធ្វើនេសាទរបស់សមាជិកទាំងអស់ឱ្យបានសមស្របទៅតាមច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ
- សហការជាមួយសមត្ថកិច្ចជលផលដើម្បីបង្ក្រាបរាល់បទល្មើសជលផលនៅក្នុងកន្លែងនេសាទសហគមន៍។ ក្នុង ករណីបន្ទាន់ និងចាំបាច់សហគមន៍នេសាទអាចស្នើសុំអន្តរាគមន៍ពីសមត្ថកិច្ចនៅជិតខាងដើម្បីឃាត់ទុកវត្ថុតាង នៃបទល្មើស និងឃាត់ខ្លួនជនប្រព្រឹត្តបទល្មើសរួចបញ្ជូនជាបន្ទាន់ទៅសមត្ថកិច្ចជលផលដើម្បីដោះស្រាយបទ ល្មើសតាមលក្ខណៈច្បាប់
- ធ្វើទំនាក់ទំនងជាមួយសហគមន៍នេសាទនានា រូបវន្តបុគ្គល ឬនីតិបុគ្គលនានា ដើម្បីផលប្រយោជន៍របស់សហគមន៍ នេសាទស្របតាមលិខិតបទដ្ឋានគតិយុត្តនានាដែលនៅជាធរមាន
- ធ្វើនេសាទ ធ្វើវារីវប្បកម្ម ប្រមូលផល លក់ ប្រើប្រាស់ និងគ្រប់គ្រងរាល់ធនធានជលផលស្របតាមកិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។

មាត្រា ១២.—

សហគមន៍នេសាទពុំមានសិទ្ធិ ÷

- លក់ ដោះដូរ ជួល ធ្វើអំណោយ ប្រវាស់ បែងចែក ខ្ចី បញ្ចាំ ឬផ្ទេរកន្លែងនេសាទសហគមន៍បានឡើយ ទោះ តាមរូបភាពណាក៏ដោយ

- ធ្វើទំនប់ ឬធ្វើនេសាទដែលបណ្តាលឱ្យរាំងស្ទះមុខព្រែក អូរ ប្រឡាយ ឬចរាចរត្រីឡើយ។ ករណីនេះអាចធ្វើបានលុះត្រាតែមានការអនុញ្ញាតពីរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទតាមសំណើរបស់នាយកដ្ឋានជលផល ក្រោយពីបានពិគ្រោះយោបល់ជាមួយស្ថាប័នពាក់ព័ន្ធ
- បែងចែកធ្វើជាកម្មសិទ្ធិឯកជននូវដីព្រៃលិចទឹក និងព្រៃកោងកាង ដីលិចទឹកព្រមទាំងកន្លែងនេសាទនៅក្នុងកន្លែងនេសាទសហគមន៍ដែលផ្តល់ឱ្យសហគមន៍នេសាទគ្រប់គ្រងដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- ចុះកិច្ចព្រមព្រៀងផ្សេងៗដែលពាក់ព័ន្ធក្នុងកន្លែងនេសាទសហគមន៍ជាមួយរូបវន្តបុគ្គល ឬនីតិបុគ្គលនានា ទោះបីក្នុងករណីស្រាវជ្រាវវិទ្យាសាស្ត្រក៏ដោយ។

មាត្រា ១៣.—

សមាជិកសហគមន៍នេសាទមានសិទ្ធិ ÷

- ចូលរួមប្រជុំមហាសន្និបាត និងបោះឆ្នោតស្មើភាពគ្នា
- បោះឆ្នោត និងឈរឈ្មោះបោះឆ្នោតក្នុងរចនាសម្ព័ន្ធគណៈកម្មការសហគមន៍នេសាទ ស្របតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ
- ទទួលព័ត៌មានអំពីស្ថានភាពសេដ្ឋកិច្ចរបស់សហគមន៍នេសាទពីគណៈកម្មការសហគមន៍នេសាទ
- ស្នើឱ្យមានការកោះប្រជុំមហាសន្និបាតវិសាមញ្ញ ដើម្បីធ្វើការពិភាក្សា និងសម្រេចលើបញ្ហាណាមួយ បើមានការស្នើសុំពីសមាជិកយ៉ាងតិចមួយភាគបី(១/៣)នៃសមាជិកទាំងអស់
- ធ្វើសំណូមពរឱ្យដាក់ចូលរបៀបវារៈនៃមហាសន្និបាតនូវបញ្ហាទាំងឡាយណាដែលមានប្រយោជន៍សម្រាប់សហគមន៍នេសាទ
- ធ្វើនេសាទជាលក្ខណៈគ្រួសារតាមច្បាប់ និងបទប្បញ្ញត្តិផ្សេងៗដែលពាក់ព័ន្ធនឹងវិស័យជលផល និងលក្ខន្តិកៈសហគមន៍នេសាទ
- ចូលរួមក្នុងសកម្មភាពទាំងអស់របស់សហគមន៍នេសាទ
- ប្តឹងតវ៉ា ឬផ្តល់ព័ត៌មានអំពីបាតុភាពទាំងឡាយដែលប៉ះពាល់ដល់ផលប្រយោជន៍របស់សហគមន៍ទៅសមត្ថកិច្ចជលផល ក្រុមប្រឹក្សាឃុំ សង្កាត់ អាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចពាក់ព័ន្ធ។

ក្នុងករណីមានសមាជិកណាម្នាក់នៃសហគមន៍នេសាទណាមួយរារាំងមិនឱ្យសមាជិកដទៃទៀតក្នុងសហគមន៍នេសាទដែលខ្លួនជាសមាជិកអនុវត្តសិទ្ធិដែលមានចែងក្នុងកថាខណ្ឌទី១នៃមាត្រានេះ ឬធ្វើឱ្យមានការប៉ះពាល់ខ្លាំងដល់ផលប្រយោជន៍សហគមន៍ ឬសមាជិកសហគមន៍នេសាទដទៃទៀត សមាជិករូបនោះអាចត្រូវព្យួរ ឬបណ្តេញចេញពីសហគមន៍ ក្រោយពីបានការពារខ្លួនចំពោះមុខគណៈកម្មការសហគមន៍នេសាទ។

សមាជិកសហគមន៍នេសាទ ត្រូវទទួលខុសត្រូវរៀងៗខ្លួន និងរួមគ្នាផងចំពោះកំហុសដែលខ្លួនបានប្រព្រឹត្តក្នុងពេលបំពេញភារកិច្ច ដោយមិនទាន់គិតដល់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌឡើយ ។

សមាជិកថ្មីដែលសុំចូលជាសមាជិកសហគមន៍ ត្រូវបញ្ជាក់អំពីការសុខចិត្តគោរពតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ ព្រមទាំងសេចក្តីសម្រេចនានារបស់មហាសន្និបាតសហគមន៍នេសាទ ។

មាត្រា ១៤.—

អ្នកប្រើប្រាស់ធនធានជលផលដែលមិនមែនជាសមាជិកសហគមន៍នេសាទអាចមានសិទ្ធិចេញ ចូល និងប្រើប្រាស់ធនធានជលផលក្នុងកន្លែងនេសាទសហគមន៍ ដោយត្រូវអនុវត្តឱ្យស្របតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងវិស័យជលផល ។

ជំពូកទី ៤
គណៈកម្មការសហគមន៍នេសាទ

មាត្រា ១៥.—

សហគមន៍នេសាទនីមួយៗត្រូវដឹកនាំដោយគណៈកម្មការមួយហៅថា "**គណៈកម្មការសហគមន៍នេសាទ**" ។

គណៈកម្មការសហគមន៍នេសាទនេះ ត្រូវជ្រើសរើសតាមការបោះឆ្នោតរបស់មហាសន្និបាតដោយសម្ងាត់ សេរី ត្រឹមត្រូវ និងយុត្តិធម៌ដែលមានសំឡេងគាំទ្រភាគច្រើនដាច់ខាតពីសមាជិកសហគមន៍នេសាទដែលបានចូលរួម ។

មាត្រា ១៦.—

បេក្ខជនដែលទទួលបានសំឡេងឆ្នោតគាំទ្រច្រើនជាងគេបង្អស់ គឺជាប្រធានគណៈកម្មការសហគមន៍នេសាទ ។ បេក្ខជនដែលទទួលបានសំឡេងឆ្នោតបន្ទាប់គឺជាអនុប្រធានគណៈកម្មការសហគមន៍នេសាទ ។

សមត្ថកិច្ចជលផល សមត្ថកិច្ចពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន ឬក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានអញ្ជើញឱ្យចូលរួមសង្កេតការណ៍ ឬសម្របសម្រួលក្នុងការបោះឆ្នោត ។ លទ្ធផលនៃការបោះឆ្នោតត្រូវបានទទួលស្គាល់ជាផ្លូវការ ទោះបីអវត្តមាននៃសមត្ថកិច្ចជលផល សមត្ថកិច្ចពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន ឬក្រុមប្រឹក្សាឃុំ សង្កាត់ក៏ដោយ ។

មាត្រា ១៧.–

សមាជិកគណៈកម្មការសហគមន៍នេសាទមានចំនួនសេសពីប្រាំ(៥)រូប ទៅដប់មួយ(១១)រូប អាស្រ័យទៅតាមស្ថានភាពជាក់ស្តែង និងសេចក្តីសម្រេចរបស់មហាសន្និបាត ដោយត្រូវលើកទឹកចិត្តឱ្យមានស្ត្រីភេទចូលរួមឈរឈ្មោះជាបេក្ខជនក្នុងគណៈកម្មការសហគមន៍នេសាទ ។

មាត្រា ១៨.–

ប្រជាពលរដ្ឋទាំងពីរភេទដែលមានសិទ្ធិ និងបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសជាគណៈកម្មការសហគមន៍នេសាទត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ÷

- ជាសមាជិកនៃសហគមន៍នេសាទសាមី
- មានសញ្ជាតិខ្មែរពីកំណើត ។

មាត្រា ១៩.–

គណៈកម្មការសហគមន៍នេសាទទទួលសិទ្ធិអំណាចក្នុងកិច្ចការដឹកនាំ និងគ្រប់គ្រងសហគមន៍នេសាទស្របតាមមាត្រា ១១ និង មាត្រា ១២ នៃអនុក្រឹត្យនេះ ។ គណៈកម្មការសហគមន៍នេសាទមានអាណត្តិប្រាំ(៥)ឆ្នាំ ហើយផុតកំណត់នៅពេលដែលមានគណៈកម្មការសហគមន៍នេសាទថ្មីដែលត្រូវបានបោះឆ្នោតជ្រើសរើសឡើងចូលកាន់តំណែងជំនួស ។

មាត្រា ២០.–

គណៈកម្មការសហគមន៍នេសាទមានតួនាទី និងភារកិច្ចដូចខាងក្រោម ÷

- រៀបចំសេចក្តីព្រាងលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ ផែនការគ្រប់គ្រង និងកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍
- ប្រតិបត្តិស្របតាមលក្ខខណ្ឌនៅក្នុងលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង និងលិខិតបទដ្ឋានពាក់ព័ន្ធផ្សេងទៀត
- ស្វែងរកជំនួយឧបត្ថម្ភគាំទ្រផ្នែកបច្ចេកទេស និងផ្នែកហិរញ្ញវត្ថុពីសមត្ថកិច្ចជលផល ស្ថាប័នពាក់ព័ន្ធ និងអ្នកផ្តល់ជំនួយផ្សេងៗក្នុងការអនុវត្តដំណើរការសហគមន៍នេសាទ
- តំណាងឱ្យសហគមន៍នេសាទក្នុងការសម្រុះសម្រួល និងដោះស្រាយទំនាស់ដែលកើតមាន
- បើកគណនី និងគ្រប់គ្រងហិរញ្ញវត្ថុសហគមន៍នេសាទ ដោយមានតម្លាភាព និងការទទួលខុសត្រូវ
- ធ្វើសេចក្តីសម្រេចលើការអភិវឌ្ឍសហគមន៍នេសាទ ដោយមានការយល់ព្រមពីសមាជិកសហគមន៍នេសាទភាគច្រើនស្របទៅតាមលក្ខន្តិកៈសហគមន៍នេសាទ កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

- ចូលរួមពិគ្រោះយោបល់ក្នុងការធ្វើបទបញ្ញានានាដែលពាក់ព័ន្ធដល់ផលប្រយោជន៍របស់សហគមន៍នេសាទ
- រាយការណ៍ និងផ្ដល់ព័ត៌មានជាបន្ទាន់នូវរាល់បទល្មើសជលផលក្នុងកន្លែងនេសាទសហគមន៍ដល់សមត្ថកិច្ចជលផល ដែលនៅជិតបំផុត
- ធ្វើការអភិរក្ស និងការពារវារិជាតនៅក្នុងកន្លែងនេសាទសហគមន៍
- អនុវត្តតួនាទីចាំបាច់ផ្សេងៗទៀត តាមការណែនាំរបស់សមត្ថកិច្ចជលផល
- ធ្វើការតវ៉ាចំពោះការមិនបន្តកិច្ចព្រមព្រៀងឱ្យសហគមន៍នេសាទ។

មាត្រា ២១.–

មានតែគណៈកម្មការសហគមន៍នេសាទទេ ដែលមានសិទ្ធិដាក់ពាក្យស្នើសុំកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ទៅនាយកដ្ឋានជលផលដើម្បីសុំការឯកភាព។

គណៈកម្មការសហគមន៍នេសាទអាចស្នើសុំជំនួយបច្ចេកទេសពីការិយាល័យជលផលខេត្ត ក្រុង ឬអ្នកដែលមានជំនាញក្នុងការគ្រប់គ្រងសហគមន៍នេសាទដើម្បីធ្វើការរៀបចំសេចក្ដីព្រាងនៃកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍។

ជំពូកទី ៥
ស្ថាប័នទទួលខុសត្រូវ

មាត្រា ២២.–

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសមត្ថកិច្ចទូទៅលើការគ្រប់គ្រងសហគមន៍នេសាទ ហើយមានតួនាទី និងភារកិច្ចដូចខាងក្រោម ÷

- ធ្វើជាអាណាព្យាបាលរបស់សហគមន៍នេសាទ
- ចេញប្រកាសទទួលស្គាល់ បដិសេធ ឬរំសាយសហគមន៍នេសាទ
- ចេញប្រកាសស្ដីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទ គំរូលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ តាមរយៈដំណើរការពិគ្រោះយោបល់
- សម្របសម្រួលជាមួយស្ថាប័នរដ្ឋ និងភាគីពាក់ព័ន្ធផ្សេងទៀតលើការអនុវត្ត និងការអភិវឌ្ឍក្នុងការគ្រប់គ្រងសហគមន៍នេសាទ
- ធ្វើអន្តរាគមន៍ក្នុងការដោះស្រាយទំនាស់របស់សហគមន៍នេសាទ

- ជួយស្វែងរកជំនួយពីគ្រប់មជ្ឈដ្ឋានដើម្បីឧបត្ថម្ភ និងគាំទ្រដល់សហគមន៍នេសាទ។

មាត្រា ២៣.-

នាយកដ្ឋានជលផលមានតួនាទី និងភារកិច្ចដូចខាងក្រោម ÷

- ពិនិត្យផ្ដល់យោបល់ជូនក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដើម្បីសម្រេចលើសំណើបង្កើតសហគមន៍នេសាទ
- ពិនិត្យ និងចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ជាមួយសហគមន៍នេសាទ
- ធ្វើសំណើទៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដើម្បីបញ្ឈប់កិច្ចព្រមព្រៀងក្នុងករណីពិនិត្យឃើញថា សហគមន៍នេសាទមិនគោរពតាមខ្លឹមសារនៃកិច្ចព្រមព្រៀង
- ពិនិត្យ និងសម្រេចលើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍
- ពិនិត្យ និងដោះស្រាយរាល់សំណើរបស់សហគមន៍នេសាទក្នុងការគ្រប់គ្រងធនធានជលផលប្រកបដោយចីរភាព
- ទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផលក្នុងកន្លែងនេសាទសហគមន៍
- ដោះស្រាយទំនាស់វិស័យជលផលក្នុងកន្លែងនេសាទសហគមន៍
- សម្របសម្រួលក្នុងការរៀបចំសហគមន៍នេសាទ កំណត់ព្រំប្រទល់កន្លែងនេសាទសហគមន៍ លក្ខន្តិកៈសហគមន៍នេសាទ ផែនការគ្រប់គ្រងសហគមន៍នេសាទ និងការធ្វើសកម្មភាពគ្រប់គ្រងធនធានជលផលរបស់សហគមន៍នេសាទ
- ផ្សព្វផ្សាយគោលនយោបាយរបស់រាជរដ្ឋាភិបាល លិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងវិស័យជលផល និងឯកសារដែលទាក់ទងនឹងសហគមន៍នេសាទ
- អប់រំ បណ្ដុះបណ្ដាល ដើម្បីបង្កើនសមត្ថភាពបច្ចេកទេសជំនាញសម្រាប់ការគ្រប់គ្រងដល់សហគមន៍នេសាទ
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តរបស់សហគមន៍នេសាទ
- ជួយស្វែងរកជំនួយពីគ្រប់មជ្ឈដ្ឋានដើម្បីឧបត្ថម្ភ និងគាំទ្រដល់សហគមន៍នេសាទ។

ជំពូកទី ៦

កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍

មាត្រា ២៤.-

កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ត្រូវភ្ជាប់មកជាមួយ ÷

- ផែនទីមាត្រដ្ឋាន ១/៥០.០០០ បញ្ជាក់ពីតំបន់ស្នើសុំបង្កើតកន្លែងនេសាទសហគមន៍ដែលមាននិយាមការភូមិសាស្ត្រច្បាស់

- បញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ និងគណៈកម្មការសហគមន៍នេសាទ
- លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ
- សេចក្តីថ្លែងការណ៍ស្តីពីគោលបំណងនៃការបង្កើតសហគមន៍នេសាទ និងការគ្រប់គ្រងធនធានជលផល ដោយមានការអះអាងអំពីការគ្រប់គ្រងធនធានជលផលប្រកបដោយចីរភាព
- ឯកសារពាក់ព័ន្ធផ្សេងៗទៀតក្នុងករណីចាំបាច់។

មាត្រា ២៥.-

សេចក្តីព្រាងនៃកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ត្រូវប្រកាសជូនដំណឹងដោយបិទផ្សាយយ៉ាងតិចសាមសិប (៣០) ថ្ងៃ នៅតាមកន្លែងសាធារណៈនានាដែលងាយមើលឃើញ នៅសាលាឃុំ សង្កាត់ ស្រុក ខណ្ឌ និង ខេត្ត ក្រុង មុននឹងដាក់សេចក្តីព្រាងនៃកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ជូននាយកដ្ឋានជលផលដើម្បីពិនិត្យ និងសម្រេច។

ក្នុងករណីមានការជំទាស់កើតឡើងក្នុងអំឡុងពេលប្រកាសជូនដំណឹង ក្រុមប្រឹក្សាឃុំ សង្កាត់ អាជ្ញាធរស្រុក ខណ្ឌ និងខេត្ត ក្រុង ត្រូវជួយសម្របសម្រួលដល់គណៈកម្មការសហគមន៍នេសាទដើម្បីដោះស្រាយទំនាស់ ឬកែសម្រួលសេចក្តីព្រាងនៃកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ តាមការស្នើឡើងដោយគណៈកម្មការសហគមន៍នេសាទ។

នីតិវិធីនៃការរៀបចំកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

មាត្រា ២៦.-

កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ មានសុពលភាពមិនលើសពីរយៈពេលបី (៣) ឆ្នាំ ចាប់ពីថ្ងៃឯកភាពដោយនាយកដ្ឋានជលផល។

គណៈកម្មការសហគមន៍នេសាទត្រូវធ្វើការស្នើសុំជាលាយលក្ខណ៍អក្សរទៅកាន់នាយកដ្ឋានជលផល រយៈពេលប្រាំមួយ (៦) ខែ មុនពេលកិច្ចព្រមព្រៀងផុតសុពលភាព ដើម្បីបន្តកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍មិនលើសពីរយៈពេលបី (៣) ឆ្នាំជាថ្មី។

ការសុំបន្តនេះ ត្រូវបានអនុញ្ញាតជូនតាមរយៈសេចក្តីជូនដំណឹងរបស់នាយកដ្ឋានជលផល ក្នុងរយៈពេលសាមសិប (៣០) ថ្ងៃ មុនថ្ងៃផុតកំណត់នៃកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍។ នាយកដ្ឋានជលផលបញ្ចប់កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ឬមិនផ្តល់ការអនុញ្ញាតឱ្យបន្ត ប្រសិនបើនាយកដ្ឋានជលផលបានផ្ញើជូនគណៈកម្មការសហគមន៍នេសាទនូវរបាយការណ៍ស្តីពីលទ្ធផលត្រួតពិនិត្យ និងវាយតម្លៃរបស់ការិយាល័យជលផលខេត្ត ក្រុងសាមីដែលមានការចូលរួមជាមួយ

គណៈកម្មការសហគមន៍នេសាទលើដំណើរការអនុវត្តការគ្រប់គ្រងកន្លែងនេសាទសហគមន៍កន្លងមក ដោយបញ្ជាក់នូវមូលហេតុ និងភស្តុតាងនៃការមិនគោរពកិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។

ក្នុងករណីដែលនាយកដ្ឋានជលផល មិនបានផ្តល់សេចក្តីជូនដំណឹងចំពោះការស្នើសុំបន្តកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ក្នុងរយៈពេលសាមសិប(៣០)ថ្ងៃ មុនថ្ងៃផុតសុពលភាព កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ត្រូវបានបន្តដោយស្វ័យប្រវត្តិ។

មាត្រា ២៧.–

កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍អាចបញ្ឈប់មុនពេលកំណត់ដោយផ្អែកលើលក្ខខណ្ឌណាមួយដូចខាងក្រោម ÷

១- ការឯកភាពគ្នារវាងភាគីទាំងអស់ជាលាយលក្ខណ៍អក្សរ។

២- ការព្រមព្រៀងគ្នាក្នុងគណៈកម្មការសហគមន៍នេសាទ និងមានការឯកភាពពីរភាគបី(២/៣) ពីសមាជិកសហគមន៍នេសាទ។

៣- ការមិនអនុវត្ត ឬអនុវត្តរំលោភធ្ងន់ធ្ងរលើលក្ខខណ្ឌកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ និងបទប្បញ្ញត្តិនានាដែលមិនធានាចីរភាពធនធានជលផល។

៤- ការយល់ឃើញរបស់រាជរដ្ឋាភិបាលនូវគោលបំណងផ្សេងមួយទៀតដែលផ្តល់ផលប្រយោជន៍សាធារណៈ និងសង្គមចំពោះព្រះរាជាណាចក្រកម្ពុជាច្រើនជាង។

ក្នុងករណីដូចចំណុចទី៤ នៃមាត្រា២៧ នៃអនុក្រឹត្យនេះ នាយកដ្ឋានជលផលត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរក្នុងរយៈពេលប្រាំមួយ(៦)ខែ មុនការបញ្ឈប់ទៅឱ្យគណៈកម្មការសហគមន៍នេសាទ ដោយបញ្ជាក់ប្រាប់ពីមូលហេតុនៃការបញ្ឈប់នោះ។ ក្នុងរយៈពេលនេះ នាយកដ្ឋានជលផលត្រូវធ្វើការពិភាក្សាសម្របសម្រួលជាមួយគណៈកម្មការសហគមន៍នេសាទចំពោះការបាត់បង់ផលប្រយោជន៍របស់សហគមន៍។

ជំពូកទី ៧

ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

មាត្រា ២៨.–

បន្ទាប់ពីមានការឯកភាពលើកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ គណៈកម្មការសហគមន៍នេសាទត្រូវរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍។

គណៈកម្មការសហគមន៍នេសាទអាចស្នើសុំជំនួយបច្ចេកទេសក្នុងការរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ពីសមត្ថកិច្ចជលផល ។

គណៈកម្មការសហគមន៍នេសាទត្រូវដាក់ស្នើផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ជូនទៅនាយកដ្ឋានជលផលតាមរយៈការិយាល័យជលផលខេត្ត ក្រុងសាមី ដើម្បីធ្វើការពិនិត្យ និងសម្រេច ។

វិធាននៃការរៀបចំផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

មាត្រា ២៩.—

ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ត្រូវមានសុពលភាពស្មើនឹងកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ។

ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ត្រូវបានពិនិត្យឡើងវិញដោយការិយាល័យជលផលខេត្ត ក្រុង រៀងរាល់ឆ្នាំ ឬមុនរយៈពេលនេះ ប្រសិនបើចាំបាច់ដើម្បីរាយការណ៍ជូននាយកដ្ឋានជលផល ។

ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ត្រូវមានការចូលរួមពីតំណាងគណៈកម្មការសហគមន៍នេសាទ ។

នាយកដ្ឋានជលផលអាចតម្រូវឱ្យគណៈកម្មការសហគមន៍នេសាទធ្វើការកែសម្រួលផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ឡើងវិញ ស្របទៅតាមលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងវិស័យជលផល ដើម្បីធានាដល់ចីរភាពនៃកន្លែងនេសាទសហគមន៍ ។

ជំពូកទី ៨
ប្រភពហិរញ្ញវត្ថុ

មាត្រា ៣០.—

ប្រភពហិរញ្ញវត្ថុរបស់សហគមន៍នេសាទបានមកពី ៖

- ភាគទានរបស់សមាជិកសហគមន៍នេសាទ
- អំណោយពីសប្បុរសជន
- ជំនួយពីរាជរដ្ឋាភិបាល អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលនានា
- ចំណូលស្របច្បាប់ផ្សេងៗទៀត

ជំពូកទី ៩
ទោសប្បញ្ញត្តិ

មាត្រា ៣១.-

ជនណាដែលប្រព្រឹត្តផ្ទុយនឹងបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន។

ជំពូកទី ១០
អវសានប្បញ្ញត្តិ

មាត្រា ៣២.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

មាត្រា ៣៣.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួងស្ថាប័ន និងអភិបាលខេត្ត ក្រុងដែលពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀង១ខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ដូចមាត្រា ៣៣
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៨០ អនក្រ.បក ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០០៥
ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ

កន្លែងនេសាទសហគមន៍ : សំដៅដល់ដែននេសាទរបស់រដ្ឋដែលបានព្រមព្រៀងផ្តល់សិទ្ធិជូនសហគមន៍មូលដ្ឋានដែលរស់នៅក្នុង ឬក្បែរដែននេសាទដើម្បីប្រើប្រាស់ជាប្រពៃណី ។

ការប្រើប្រាស់ប្រកបដោយចីរភាព : សំដៅដល់ការប្រើប្រាស់ធនធានជលផល ដោយធានារក្សានូវប្រភពធនធានជលផលនោះឱ្យបានគង់វង្សសម្រាប់ជាផលប្រយោជន៍ដល់មនុស្សគ្រប់ជំនាន់ ។

កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ : សំដៅដល់ការព្រមព្រៀងមួយជាលាយលក្ខណ៍អក្សររវាងសហគមន៍នេសាទ និងនាយកដ្ឋានជលផលដែលបានផ្តល់ និងធានាសិទ្ធិរបស់សហគមន៍នេសាទក្នុងកន្លែងនេសាទជាក់លាក់ណាមួយ ។

ជំនួយ : សំដៅដល់អំណោយ ឬកម្ចី ។

ទ្រព្យសម្បត្តិសាធារណៈ : សំដៅដល់ទ្រព្យដែលត្រូវរក្សាឱ្យគង់រូបតាមធម្មជាតិរបស់វា ដើម្បីទុកឱ្យអ្នករួមសង្គមប្រើប្រាស់ជាអង្វែងទៅ ។ ទ្រព្យទាំងនេះស្ថិតនៅជាប្រយោជន៍សាធារណៈ មិនអាចលក់ ដូរ និងគ្មានកំណត់អាជ្ញាយុកាលទេ ។

បទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ : សំដៅដល់លក្ខខណ្ឌដែលបានអនុម័តដោយមហាសន្និបាតសហគមន៍នេសាទស្តីពីការប្រតិបត្តិផ្ទៃក្នុងរបស់សហគមន៍នេសាទ ។

ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ : សំដៅដល់ឯកសារដែលបានរៀបចំឡើងដោយសហគមន៍នេសាទ និងមានការឯកភាពពីនាយកដ្ឋានជលផល ដោយមានការវាយតម្លៃហេតុប៉ះពាល់សង្គមបរិស្ថាន និងបញ្ជាក់លំអិតអំពីនីតិវិធី បទបញ្ជា និងវិធានការពាក់ព័ន្ធនឹងការរៀបចំប្រើប្រាស់កន្លែងនេសាទសហគមន៍ប្រកបដោយចីរភាព ។

លក្ខន្តិកៈសហគមន៍នេសាទ : សំដៅដល់"សេចក្តីកំណត់ដាច់ស្រេច" ដែលបានអនុម័តដោយមហាសន្និបាតសហគមន៍នេសាទ ស្របតាមគំរូនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

សហគមន៍នេសាទ : សំដៅដល់ក្រុមប្រជាពលរដ្ឋខ្មែរដែលរស់នៅក្នុងភូមិមួយ ឬច្រើនក្នុងព្រះរាជាណាចក្រកម្ពុជា ហើយដែលបានយល់ព្រមសហការគ្នាចូលរួមគ្នាដោយស្ម័គ្រចិត្តក្នុងគោលបំណងចូលរួមគ្រប់គ្រង អភិរក្ស អភិវឌ្ឍ ប្រើប្រាស់ធនធានជលផលនៅតាមមូលដ្ឋានប្រកបដោយចីរភាព និងការពារសិទ្ធិ ព្រមទាំងផលប្រយោជន៍ប្រជាពលរដ្ឋខ្មែរ ស្របតាមលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងវិស័យជលផល ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:.....៨១...អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការប្រើប្រាស់គណនី

ឯកជនតាងបនិយកម្មសហគ្រាសសាធារណៈ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសអោយប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សំរាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ១១/នស /៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ នឹងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ នឹងត្រូវបានកែប្រែដោយច្បាប់ ស្តីពីវិសោធនកម្ម មាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០២/០២០ ចុះថ្ងៃទី ៣០ ខែ ធ្នូ ឆ្នាំ ២០០២
